# មាតិកា

## I. ក្រុមប្រឹក្សាធម្មនុញ្ញ

០៥-៩-២០១៣ -សេចក្ដីសម្រេចលេខ ១៤២/០១៧/២០១៣ កបធ.ច ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២៤០/០៤៤/២០១៣ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៣ ៨៥៧៤

០៦-៩-២០១៣ -សេចក្ដីសម្រេចលេខ ១៤៣/០១៨/២០១៣ កបធ.ច ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២៣៩/០៤៣/២០១៣ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៣ ៨៦០០

## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ

១១-៩-២០១៣ -អនុក្រឹត្យលេខ ៤៨១ អនក្រ.បក ស្ដីពី ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស សានកូ ខេមបូ ៨៦២៤

០៥-៧-២០១៣ -អនុក្រឹត្យលេខ ៨៧៩ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៨៦២៧

០៥-៧-២០១៣ -អនុក្រឹត្យលេខ ៨៨០ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨៦២៩

០៥-៧-២០១៣ -អនុក្រឹត្យលេខ ៨៨១ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ៨៦៣១

០៥-៧-២០១៣ -អនុក្រឹត្យលេខ ៨៨២ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៨៦៣៣

០៨-៧-២០១៣ -អនុក្រឹត្យលេខ ៨៨៣ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៨៦៣៥

០៨-៧-២០១៣ -អនុក្រឹត្យលេខ ៨៨៤ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨៦៣៦

០៨-៧-២០១៣ -អនុក្រឹត្យលេខ ៨៨៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨៦៣៨

## III.ការិយាល័យក្រសួង

### ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៩-៨-២០១៣ -ប្រកាសលេខ ៦៦៥ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេស៊ា លីឌើរ អ៊ិនធើណេសិនណល (ខេមបូឌា) បង្កើតរោងចក្រ ផលិតកង់ជិះ ៨៦៤០

១៩-៨-២០១៣ -ប្រកាសលេខ ៦៦៦ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ៃ លី ផេកខេកជីង (ខេមបូឌា) បង្កើតរោងចក្រ ផលិតថង់ និងសម្ភារៈវេចខ្ចប់ពីផ្លាស្ទិក ៨៦៤៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៤០/០៤៤/២០១៣

ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៤២/០១៧/២០១៣ កបធ.ច

ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់លោកជំទាវ **កែ សុវណ្ណរតនី** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ផ្ទេរសិទ្ធិជូនលោកជំទាវ **កែ សុវណ្ណរតនី** ជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ មណ្ឌលខេត្តសៀមរាប
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៩៧៤/១៣ គ.ជ.ប ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣
- បានឃើញភស្តុតាងរបស់ដើមបណ្តឹង រួមមាន : បញ្ជីបោះឆ្នោតឆ្នាំ២០១២ ឯកសារទម្រង់ ១១០៤ រូបថត និង វីស៊ីឌី
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកជំទាវ **កែ សុវណ្ណរតនី** កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយបញ្ជីបោះឆ្នោតឆ្នាំ២០១២ ចំនួន ០២ ដុំ មាន ២៤៣ សន្លឹក ទម្រង់ ១១០៤ ចំនួន ១១ ការិយាល័យ ទម្រង់ ១១០៤ ចំនួន ៣២ ការិយាល័យ រូបថតចំនួន ៤៣ សន្លឹក និង វីស៊ីឌី មួយ
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ អមដោយសារណាការពារចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ ចំនួន ០៤ ទំព័រ
- បានឃើញសេចក្តីសម្រេចលេខ ៣០/២០១៣ កបធ.សសរ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តសៀមរាប
- បានឃើញលិខិតលេខ ០៤៥/២០១៣ កបធ.ច ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ចាត់តាំងសមាជិកក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីចូលរួមស្រាវជ្រាវ ស៊ើបអង្កេតការបើកកញ្ចប់សុវត្ថិភាព " ក "

ចំនួន ១២ ការិយាល័យ មណ្ឌលខេត្តសៀមរាបប្រព្រឹត្តទៅនៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញកំណត់ហេតុស្តីពីការផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព " ក " មួយចំនួននៅមណ្ឌលខេត្តសៀមរាប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៩០៦/១៣ គ.ជ.ប ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣
- បានឃើញលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិរបស់លោកជំទាវ **កែ សុវណ្ណរតន៍** ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១៣ ប្រគល់សិទ្ធិជូនលោកមេធាវី **ជួង ជូងី** និងលោកមេធាវី **កែត ឃី** ដើម្បីការពារនូវសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់គណបក្សសង្គ្រោះជាតិ ចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងសំណុំរឿងលេខ ២៤០/០៤៤/២០១៣ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣
- បានឃើញលិខិតតំណាងដោយអាណត្តិ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **ជួង ជូងី** និងពាក្យសុំតំណាងដោយអាណត្តិ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **កែត ឃី**
- បានឃើញសេចក្តីសម្រេចលេខ ៥២/២០១៣ កបធ.ច ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់លោកជំទាវ **កែ សុវណ្ណរតន៍** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ធម្មនុញ្ញបានទទួលនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៨ និង ២០ នាទី គឺស្ថិតក្នុងអាជ្ញា-យុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ និង ចំណុចទី២ នៃមាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងរបស់លោកជំទាវ **កែ សុវណ្ណរតន៍** មកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់លោកជំទាវ **កែ សុវណ្ណរតន៍** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជានៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ គឺប្តឹងតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប ។ ដើមបណ្តឹងបានរៀបរាប់ថា នៅមណ្ឌលខេត្តសៀមរាបមានភាពមិនប្រក្រតីធ្ងន់ធ្ងរក្នុងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដែលមន្ត្រីបោះឆ្នោតបានបំពានច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ព្រមទាំងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ដែលជាហេតុធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិដែលត្រូវទទួលបានក្នុងមណ្ឌលខេត្តសៀមរាប ។ ភាពមិនប្រក្រតីធ្ងន់ធ្ងរទាំងនេះហើយដែលដើមបណ្តឹងទាមទារមកក្រុមប្រឹក្សាធម្មនុញ្ញនូវ ៣ ចំណុចដូចតទៅ ៖ ១-ឱ្យ គ.ជ.ប រៀបចំការបោះឆ្នោតសាជាថ្មី ចំនួន ១៦ ការិយាល័យ នៃស្រុកស្វាយលើ និងស្រុកវ៉ារិន គឺការិយាល័យលេខ ១១៣៦ ១១៥៣ ១០៩៩ ០៦៩៧ ០៦៩៥ ០៨៦៤ ១១៣៧ ១១៣៨ ១១១៦ ១០៥៧ ១១១៥ ១១៤០ ១១៤៣ ១១៧៣ ១១៤២ និង ១១៧២ ព្រោះការិយាល័យទាំង ១៦ នេះ មានការកៀងគរទាហានដែលគ្មានទីលំនៅក្នុងឃុំ ដោយមានការដឹកទាហានតាមរថយន្តយោធាមកបោះឆ្នោតនៅការិយាល័យបោះឆ្នោតទាំងនោះ ។ ទង្វើបែបនេះបានបំពានលើបទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ត្រង់ចំណុច ៧.៤.១ ចំណុច ៧.៤.៣ និងបំពានលើមាត្រា ៥៤ ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២-ឱ្យ គ.ជ.ប ពិនិត្យផ្ទៀងផ្ទាត់ រាប់សន្លឹកឆ្នោត និងផ្តល់សុពលភាពលើសន្លឹកឆ្នោតមិនបានការឡើងវិញ ចំនួន ២០០ ការិយាល័យ ក្នុងមណ្ឌលខេត្តសៀមរាប តែនៅពេលចូលមកបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកជំទាវយល់ព្រមបន្ថយមកត្រឹមតែ ៣២ ការិយាល័យវិញ ៣-ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" ដកយកទម្រង់ ១១០២ និង ១១០៨ មកផ្ទៀងផ្ទាត់លទ្ធផលជាមួយទម្រង់ ១១០៤ ចំនួន ៧៥ ការិយាល័យ ។ នៅពេលចូលមកបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដើមបណ្តឹងបានយល់ព្រមបន្ថយមកត្រឹមតែ ១១ ការិយាល័យវិញ

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោកជំទាវ **កែ សុវណ្ណរតន៍** អមដោយលោកមេធាវី **កែត ឃី** និងលោកមេធាវី **ជួង ជូងី** តំណាងដោយអាណត្តិបានរៀបរាប់ឡើងវិញនូវខ្លឹមសារដែលមានចែងក្នុងពាក្យបណ្តឹង ព្រមទាំងលើកអំពីអង្គហេតុ និងអង្គច្បាប់ ដើម្បីដាក់បន្ទុកលើគណៈកម្មាធិការ

ជាតិរៀបចំការបោះឆ្នោត។ អំពីការបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ១២ ការិយាល័យ នៅមណ្ឌលខេត្តសៀមរាប ដើម្បីផ្ទៀងផ្ទាត់ ដើមបណ្តឹងបានលើកឡើងថា មានចំនួនការិយាល័យតិចពេក មិនស្របតាមទិសដៅ និងសំណូមពរ។ ដើមបណ្តឹងបានលើកអំពីការប្រព្រឹត្តល្មើសច្បាប់ និងបទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ អំពីករណីយករថយន្តយោធាដឹកទាហានឈរជើងនៅសមរភូមិមុខ តាមខ្សែក្រវ៉ាត់ព្រំដែនទៅបោះឆ្នោតនៅ ១៦ ការិយាល័យ នៃស្រុកស្វាយលើ និងស្រុកវ៉ារិន។ ជាចុងក្រោយ តំណាងគណបក្សសង្គ្រោះជាតិសំណូមពរ ៖ ១-បដិសេធសេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចោលទាំងស្រុង ២-អនុញ្ញាតឱ្យ គ.ជ.ប ធ្វើការរាប់សន្លឹកឆ្នោតបានការ និងផ្ទៀងផ្ទាត់ឡើងវិញលើសន្លឹកឆ្នោតមិនបានការចំនួន ២០០ ការិយាល័យ ក្នុងខេត្តសៀមរាប និងផ្ទៀងផ្ទាត់ទម្រង់ ១១០២ ១១០៨ និង ១១០៤ ចំនួន ៧៥ ការិយាល័យ ៣-អនុញ្ញាតឱ្យ គ.ជ.ប បោះឆ្នោតឡើងវិញចំនួន ១៦ ការិយាល័យ នៅស្រុកស្វាយលើ និងស្រុកវ៉ារិន ៤-ចាត់ឱ្យមានការស៊ើបអង្កេតឡើងវិញ ថាតើកំហុសទាំងអស់ខាងលើនេះ មានការបង្គាប់បញ្ជាពីត្រឹមថ្នាក់ណា? ត្រឹមថ្នាក់សមាជិកគណៈកម្មការការិយា-ល័យបោះឆ្នោត ឬថ្នាក់សមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់ រៀបចំការបោះឆ្នោត ឬពីថ្នាក់សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះទៅ ៥-សុំឱ្យមានការផ្តន្ទាទោសលើជនប្រព្រឹត្តល្មើស តាមមាត្រា ១២៥ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ

- យល់ឃើញថា ឯកឧត្តម **ឯម សូជាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅពេលឆ្លើយបំភ្លឺចំពោះបុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ អមដោយសារណាការពារចំនួន ០៨ ទំព័រ ក៏ដូចជានៅពេលសវនាការជាសាធារណៈ បានបញ្ជាក់ថា គ.ជ.ប ក្នុងការដោះស្រាយបណ្តឹងលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត គឺអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១១៤ មាត្រា ១១៥ ថ្មី និងមាត្រា ១១៦ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ។ ចំពោះការតវ៉ាទាំងឡាយរបស់ដើមបណ្តឹង គ.ជ.ប បានដោះស្រាយតាមដំណាក់កាលនីមួយៗ ដែលមានខ្លឹមសារដូចតទៅ ៖ ១-ពាក្យបណ្តឹង និងចម្លើយអះអាងរបស់លោកជំទាវ **កែ សុវណ្ណរតន៍** មិនបានបញ្ជាក់អំពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត តាមមាត្រា ១១៤

នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះឡើយ ២-ជាក់ស្តែងនៅខេត្តសៀមរាបទាំងមូល ដែលមានការិយាល័យបោះឆ្នោតសរុប ១.១៨១ ការិយាល័យ ក្នុងឃុំ សង្កាត់ចំនួន ១០០ នៅដំណាក់កាលមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ដែលដាក់នៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មានបណ្តឹងតែ ១៦ បណ្តឹង ក្នុងនោះមានបណ្តឹងសុំឱ្យផ្តន្ទាទោសមន្ត្រីបោះឆ្នោតចំនួន ៦ សុំឱ្យផ្តន្ទាទោសជនមិនមែនជាមន្ត្រីបោះឆ្នោតចំនួន ៧ និងប្តឹងពីភាពមិនប្រក្រតីចំនួន ៣ ។ បណ្តឹងដែលត្រូវបានប្តឹងបន្តមកគណៈកម្មការរៀបចំការបោះឆ្នោតខេត្តសៀមរាបចំនួន ១០ បណ្តឹង និងបន្តប្តឹងមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានតែ ៦ បណ្តឹងតែប៉ុណ្ណោះ ៣-ក្នុងការទទួល និង ដោះស្រាយបណ្តឹងទាក់ទងថ្ងៃស និងថ្ងៃបោះឆ្នោត និងក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោត ក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្តទាំង ២៤ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអនុវត្តតួនាទី និងសិទ្ធិអំណាចរបស់ខ្លួនស្របតាម ច.ប.ត.រ ចាប់ពីមាត្រា ១០៩ ថ្មី មាត្រា ១១០ មាត្រា ១១១ ថ្មី មាត្រា ១១២ ថ្មី និងមាត្រា ១១៣ និងស្របតាម ប.ន.ត.រ នៅមុនពេលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។ ជាក់ស្តែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ គឃ/សប គច/ខប និង គ.ជ.ប បានអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមលំដាប់ថ្នាក់ ដោយមានការអញ្ជើញចូលរួមពីតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ៤-លទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ១២ ការិយាល័យ នៃខេត្តសៀមរាប ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោតក្នុងទម្រង់ ១១០២ ១១០៨ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត ដែលបានធ្វើនៅ គ.ជ.ប តាមសេចក្តីសម្រេចលេខ ៣០/២០១៣ កបច.សសរ ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចមានក្នុងកំណត់ហេតុស្តីពីការផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តសៀមរាប។ ក្នុងនោះទោះបីជាមានកញ្ចប់សុវត្ថិភាព "ក" មួយចំនួនមិនបានបិទការសុវត្ថិភាព ដែលជាការធ្វេសប្រហែសក្នុងការវេចខ្ចប់ ប៉ុន្តែជារួមសំឡេងឆ្នោតដែលគណបក្សនយោបាយនីមួយៗ ទទួលបានមានភាពត្រឹមត្រូវទាំងស្រុង ៥-សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធ្វើឡើងស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និង បទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

នីតិកាលទី៥ ឆ្នាំ២០១៣ ហើយ។ ឆ្លើយនឹងសំណួររបស់ក្រុមប្រឹក្សាជម្រះ ឯកឧត្តម **ឯម សូផាត** បានបញ្ជាក់ថា ភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំដល់ការបោះឆ្នោតសាឡើងវិញ គឺករណីប្រធានសន្តិអសន្តិសុខ មិនអាចបើកការិយាល័យបោះឆ្នោតបាន ឬបើកការិយាល័យបានតែបន្តិច រួចបិទទៅវិញ ក្រោយពីមានការសម្រេចពី គ.ជ.ប ។ ចំពោះករណីរថយន្តយោធាដឹកទាហានពីខ្សែក្រវ៉ាត់ព្រំដែនសមរភូមិមុខមកបោះឆ្នោត តំណាង គ.ជ.ប បំភ្លឺថា នេះជាករណីពិសេសសម្រាប់តែតំបន់នោះ ហើយបានធ្វើតាំងពីការបោះឆ្នោតឆ្នាំ២០០៨ និងឆ្នាំ២០១២ មក ពីព្រោះអ្នកទាំងនោះមានបន្ទាយបោះទីតាំងនៅតំបន់នោះជាយូរយាមកហើយ។ ការសម្រេចចំពោះករណីពិសេសនេះ ជាឆន្ទានុសិទ្ធិរបស់ គ.ជ.ប ដែលច្បាប់ផ្តល់សិទ្ធិពេញលេញឱ្យ គ.ជ.ប អនុវត្តសមត្ថកិច្ច។ ឯកឧត្តម **ឯម សូផាត** សំណូមពរសុំតម្កល់សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល

- យល់ឃើញថា ការដឹកជញ្ជូនកងទ័ពតាមរថយន្តរបស់អង្គភាពយោធាទៅបោះឆ្នោត ពិតជាបំពានលើប្រការ ៧.៤ ចំណុច ៧.៤.១ និងចំណុច ៧.៤.៣ នៃបទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ដែលប្រកាសឱ្យប្រើដោយសេចក្តីប្រកាសលេខ ០៦៨/១៣ គ.ជ.ប ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ រីឯការបោះឆ្នោតនៅ ១៦ ការិយាល័យក្នុងស្រុកស្វាយលើ និងស្រុកវ៉ារិន ពុំមានបាតុភូតដែលនាំឱ្យប៉ះពាល់ដល់ភាពសម្ងាត់ និងភាពសេរីនៃការបោះឆ្នោតទេ
- យល់ឃើញថា តាមការចុះបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ១២ ការិយាល័យនៅគណៈកម្មាធិការជាតិ-រៀបចំការបោះឆ្នោត ឃើញថាមានកញ្ចប់សុវត្ថិភាព "ក" ចំនួន ០៦ ការិយាល័យមិនមានបិទការសុវត្ថិភាព និង ០១ ការិយាល័យមានបិទការសុវត្ថិភាព តែរហែក និងមិនបានចាក់សោឃ្លុំកញ្ចប់ "ខ" ចំនួន ០២ ការិយាល័យ មិនបានសរសេរលេខកូដការិយាល័យលើកញ្ចប់ "ក" ខ្លះ និងលើក្រដាសធំកត់ត្រាសំឡេងឆ្នោតខ្លះ។ ក្រោយពីការពិនិត្យផ្ទៀងផ្ទាត់សំឡេងឆ្នោតក្នុងកញ្ចប់សុវត្ថិភាព "ក" ទាំង ១២ ការិយាល័យ នៅក្រុងសៀមរាប និងនៅស្រុកពួក ឃើញថា សំឡេងឆ្នោតរបស់គណបក្សសង្គ្រោះជាតិ និងសំឡេងឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា ក្នុងទម្រង់ ១១០២ ទម្រង់ ១១០៨ និង ក្រដាសធំកត់ត្រាសំឡេងឆ្នោត មិនមានការប្រែប្រួលទេ លើកលែងតែ ២ ការិយាល័យ គឺការិយាល័យលេខ ០៦៧៣ (ឃុំល្វា) សំឡេងឆ្នោតរបស់គនបក្សប្រជាជនកម្ពុជាក្នុងទម្រង់ ១១០២ និង ទម្រង់ ១១០៨ និង ទម្រង់ ១១០៤ មានតួលេខខុសគ្នា ពោលគឺក្នុងទម្រង់ ១១០៨ និង ១១០៤ មានចំនួន ២៩៧ សំឡេង

ឯក្នុងទម្រង់ ១១០២ មានតែ ២៧២ សំឡេង (លំអៀង ២៥ សំឡេង) និង ការិយាល័យលេខ ០៤៤២ ក្នុងទម្រង់ ១១០២ និង ទម្រង់ ១១០៨ សន្លឹកឆ្នោតក្នុងហិបមានចំនួន ៣៥៣ សន្លឹក ដែលតួលេខនេះ ខុសគ្នានឹងទម្រង់ ១១០៤ របស់គណបក្សសង្គ្រោះជាតិ មាន ៣៥៩ សន្លឹក (លំអៀង ០៦ សំឡេង) ។ សូមអានឧបសម្ព័ន្ធស្តីពីកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តសៀមរាប ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ការភាន់ច្រឡំក្នុងការសរសេរតួលេខនេះ មិនមែនជាភាពមិនប្រក្រតីធ្ងន់ធ្ងរធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនោះទេ។ ការមិនបកប្លាស្ទិកថ្លាចេញ ធ្វើឱ្យកញ្ចប់សុវត្ថិភាព "ក" ចំហរ និងការរហែកកញ្ចប់សុវត្ថិភាព "ក" ជាកំហុសរបស់មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំង ៧ ការិយាល័យ។ មន្ត្រីដែលធ្វើការងារនោះផ្ទាល់នៅការិយាល័យទាំង ៧ ការិយាល័យនេះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់កំណត់។ ដោយឡែកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាអាណាព្យាបាលពីលើ ក៏ត្រូវទទួលខុសត្រូវខាងសីលធម៌អំពីការងារគ្រប់គ្រងរបស់ខ្លួន

- យល់ឃើញថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ នៅមណ្ឌលខេត្តសៀមរាប សរុប ១.១៨១ ការិយាល័យ ការបោះឆ្នោតពុំមានជួបករណីប្រធានសក្តិ ពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋក្នុងមណ្ឌលបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៦៨,៦៦ ភាគរយ
- យល់ឃើញថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ លើកលែងតែការសម្រេចមិនទទួលបណ្តឹងតវ៉ានឹងការដឹកជញ្ជូនកងទ័ពតាមរថយន្តយោធាទៅបោះឆ្នោតដែលបំពានលើប្រការ ៧.៤ ចំណុច ៧.៤.១ និងចំណុច ៧.៤.៣ នៃបទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ។

## សម្រេច

## ចំពោះមុខគូភាគី

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោកជំទាវ **កែ សុវណ្ណរតន៍** ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការ លើកលែងតែការសម្រេចមិនទទួល

បណ្តឹងតវ៉ានឹងការដឹកជញ្ជូនកងទ័ពតាមរថយន្តយោធាទៅបោះឆ្នោតដែលបំពានលើប្រការ ៧.៤ ចំណុច ៧.៤.១ និងចំណុច ៧.៤.៣ នៃបទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ។

**មាត្រា ៣.-** គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ចំពោះការបំពានលើប្រការ ៧.៤ ចំណុច ៧.៤.១ និង ចំណុច ៧.៤.៣ នៃបទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ។

**មាត្រា ៤.-** ប្រគល់ភារកិច្ចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាត់វិធានការដាក់ទណ្ឌកម្មលើមន្ត្រីការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតទាំង ៧ ការិយាល័យ នៅឃុំរើល សង្កាត់ក្របីរៀល សង្កាត់ស្វាយដង្គុំ និង សង្កាត់ស្លក្រាម ដែលបានប្រព្រឹត្តខុស។

**មាត្រា ៥.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាធំនុំជម្រះ**

**ប្រធាន**

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចលេខ ១៤២/០១៧/២០១៣ កបធ.ច
ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

# កំណត់ហេតុ
## ស្តីពី
## ការផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព "ក" មួយចំនួន នៅមណ្ឌលខេត្តសៀមរាប

- យោងសេចក្ដីសម្រេចលេខ ៣០/២០១៣ កបធ.សសរ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- យោងលិខិតបង្គាប់ការលេខ ៨៧៨/១៣ គ.ជ.ប ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ឆ្នាំពីរពាន់ដប់បី ខែសីហា ថ្ងៃសុក្រ ទីសាមសិប វេលាម៉ោងប្រាំពីរ និងសែសិបនាទីព្រឹក នៅសាលសន្និសីទនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តសៀមរាប នៅក្រុងសៀមរាប សង្កាត់ក្របីរៀល ការិយាល័យបោះឆ្នោតលេខ ០២៨៣ និង ០២៨៥ សង្កាត់ស្វាយដង្គុំ ការិយាល័យបោះឆ្នោតលេខ ០៤២៥ និង ០៤៤២ និងសង្កាត់ស្លក្រាម ការិយាល័យបោះឆ្នោតលេខ ០៨១៧ និងនៅស្រុកពួក ឃុំរើល ការិយាល័យបោះឆ្នោតលេខ ០៣២៣ ០៣២៤ និង ០៣២៦ ឃុំល្វា ការិយាល័យបោះឆ្នោតលេខ ០២៩៤ ០៦៧៣ និង ០៧១៨ និងឃុំត្រីញ័រ ការិយាល័យបោះឆ្នោតលេខ ០៣៨៦ ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោត ក្នុងទម្រង់បែបបទលេខ ១១០២ និងទម្រង់បែបបទលេខ ១១០៨ និងក្រដាសកត់ត្រាសំឡេងឆ្នោត ក្រោមការត្រួតពិនិត្យរបស់ក្រុមស៊ើបអង្កេតក្រុមប្រឹក្សាធម្មនុញ្ញ។

ជាកិច្ចចាប់ផ្ដើម ក្រុមត្រួតពិនិត្យនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានជម្រាបអំពីនីតិវិធីនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងយាង និងអញ្ជើញតំណាងក្រុមប្រឹក្សាធម្មនុញ្ញ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អ្នកសារព័ត៌មានជាតិ អន្តរជាតិ ចូលរួមពិនិត្យការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តសៀមរាប នៅក្រុងសៀមរាប សង្កាត់ក្របីរៀល ការិយាល័យបោះឆ្នោតលេខ ០២៨៣ និង ០២៨៥ សង្កាត់ស្វាយដង្គុំ ការិយាល័យបោះឆ្នោតលេខ ០៤២៥ និង ០៤៤២ និងសង្កាត់ស្លក្រាម ការិយាល័យបោះឆ្នោតលេខ ០៨១៧ និងនៅស្រុកពួក ឃុំរើល ការិយាល័យបោះឆ្នោតលេខ ០៣២៣ ០៣២៤ និង ០៣២៦ ឃុំល្វា ការិយាល័យបោះឆ្នោតលេខ ០២៩៤ ០៦៧៣ និង ០៧១៨ និងឃុំត្រីញ័រ ការិយាល័យបោះឆ្នោតលេខ ០៣៨៦ ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោត ក្នុងទម្រង់បែបបទលេខ ១១០២ និងទម្រង់បែបបទលេខ ១១០៨ និងក្រដាសកត់ត្រាសំឡេងឆ្នោត ក្រោមការត្រួតពិនិត្យរបស់ក្រុមស៊ើបអង្កេតក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមត្រួត

ពិនិត្យ បានធ្វើការបើកកញ្ចប់សុវត្ថិភាព "ក" ធ្វើការផ្ទៀងផ្ទាត់ម្តងមួយៗការិយាល័យ នៅចំពោះមុខតំណាងក្រុមប្រឹក្សាធម្មនុញ្ញ គណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អ្នកសារព័ត៌មានជាតិ អន្តរជាតិ។

ឯកឧត្តម គួយ ប៊ុនរឿន តំណាងគណបក្សសង្គ្រោះជាតិ បានមានប្រសាសន៍ថា ខ្ញុំថ្លែងអំណរគុណចំពោះក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានសម្រេចឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" ខ្ញុំសូមជម្រាបអំពីបរិបទនៃពាក្យបណ្តឹងរបស់ទូលបង្គំ ខ្ញុំបាទ ករណីទី១ ស្នើសុំបោះឆ្នោតឡើងវិញ ១៦ ការិយាល័យ។ ករណីទី២ ស្នើសុំឲ្យបើកកញ្ចប់សុវត្ថិភាព "ក" មានចំនួន ២០០ការិយាល័យពិនិត្យរាប់សន្លឹកឆ្នោត និងផ្តល់សុពលភាពលើសន្លឹកឆ្នោតមិនបានការឡើងវិញ។ ករណីទី៣ ស្នើសុំឲ្យបើកកញ្ចប់សុវត្ថិភាព "ក" និងផ្ទៀងផ្ទាត់ទម្រង់ ១១០២ ទម្រង់ ១១០៨ ជាមួយនឹងទម្រង់ ១១០៤ ចំនួន ៧៥ ការិយាល័យ។ ប៉ុន្តែក្រុមប្រឹក្សាធម្មនុញ្ញសម្រេចឲ្យតែចំនួន ១២ ការិយាល័យ នៅក្នុង ២០០ការិយាល័យដែលស្នើសុំបើកកញ្ចប់សុវត្ថិភាព "ក" ពិនិត្យរាប់សន្លឹកឆ្នោត និងផ្តល់សុពលភាពលើសន្លឹកឆ្នោតមិនបានការឡើងវិញ មាននៅក្នុងឧបសម្ព័ន្ធ២ ដែលខុសពីគោលដៅ និងគោលបំណងរបស់ទូលបង្គំ គឺខុសពីកម្មវត្ថុបណ្តឹង និងកំណត់ហេតុនៃការសាកសួរនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ នៅក្រុមប្រឹក្សាធម្មនុញ្ញ ដូច្នេះ មិនមែនស្នើសុំធ្វើការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនោះទេ។ ទូលបង្គំស្នើសុំឲ្យបន្តនីតិវិធីឲ្យរាប់ពិនិត្យរាប់សន្លឹកឆ្នោត និងផ្តល់សុពលភាពលើសន្លឹកឆ្នោតមិនបានការឡើងវិញ មាននៅក្នុងឧបសម្ព័ន្ធ២ (មានចំនួន ២០០ការិយាល័យ) បានច្រើនជាង ១២ ការិយាល័យនេះតទៅទៀត។ នៅពេលដែលលេខាបានរាយការណ៍អំពីបទបញ្ជាផ្ទៃក្នុងទូលបង្គំមានសេចក្តីរីករាយ ប៉ុន្តែករណីនេះ មិនមែនជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទេ គឺជាយន្តការរបស់ក្រុមប្រឹក្សាធម្មនុញ្ញបើមានបញ្ហាអ្វីត្រូវចោទសួរទៅក្រុមប្រឹក្សាធម្មនុញ្ញ។

ឯកឧត្តម ពិត តាំងសាន តំណាងក្រុមប្រឹក្សាធម្មនុញ្ញ មានប្រសាសន៍ថា ការដែលក្រុមប្រឹក្សាធម្មនុញ្ញមកនេះ គឺអនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែលបានសម្រេចរួចហើយ ដូចដែលលេខាធិការបានអាន មានចែងនៅក្នុងប្រការ ១ ដែលក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" មណ្ឌលខេត្តសៀមរាប នៅក្រុងសៀមរាប សង្កាត់ក្របីរៀល ការិយាល័យបោះឆ្នោតលេខ ០២៨៣ និង ០២៨៥ សង្កាត់ស្វាយដង្គុំ ការិយាល័យបោះឆ្នោតលេខ ០៤២៥ និង ០៤៤២ និងសង្កាត់ស្លក្រាម ការិយាល័យបោះឆ្នោតលេខ ០៤១៧ និងនៅស្រុកពួក ឃុំរើល ការិយាល័យបោះឆ្នោតលេខ ០៣២៣ ០៣២៤ និង ០៣២៦ ឃុំល្វា ការិយាល័យបោះឆ្នោតលេខ ០២៩៤ ០៦៧៣ និង ០៧១៨ និងឃុំត្រីញ័រ ការិយាល័យបោះឆ្នោតលេខ ០៣៤៦ ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោត ក្នុងទម្រង់បែបបទលេខ ១១០២ និងទម្រង់បែបបទលេខ ១១០៨ និងក្រដាសកត់ត្រាសំឡេងឆ្នោត។ ខ្ញុំសូមបញ្ជាក់ថា គណបក្សសង្គ្រោះជាតិបានស្នើសុំទៅក្រុមប្រឹក្សាធម្មនុញ្ញ បង្រួមចំនួន ២០០ ការិយាល័យមកចំនួន ៣២ ការិយាល័យ, និងបង្រួមពី ៧៥ការិយាល័យមក ១១ ការិយាល័យវិញ។ ខ្ញុំសូមជម្រាបថា ចំពោះការសម្រេចនេះ មិនមែនជាការសម្រេចបុគ្គលទេ គឺជាការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល។

លោកជំទាវ កែ សុវណ្ណរតន៍ តំណាងគណបក្សសង្គ្រោះជាតិ មានប្រសាសន៍ថា ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺផ្ទុយគ្នាពីការសំណូមពរនៃបណ្តឹង និងកំណត់ហេតុឆ្លើយបំភ្លឺកាលពីថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៣ របស់នាងខ្ញុំនៅក្រុមប្រឹក្សាធម្មនុញ្ញ ហើយករណីដែលធ្ងន់ធ្ងរនោះ គឺមានចំនួន ២០០ ការិយាល័យដែលមានសន្លឹកឆ្នោតមិនបានការច្រើន។ ចំនួនដែលនាងខ្ញុំចង់បាននោះ មានចំនួន ៣២ ការិយាល័យដែលមានបញ្ហាធ្ងន់ធ្ងរ។ សំណូមពរនៃបណ្តឹងរបស់នាងខ្ញុំចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ គោរពជូនក្រុមប្រឹក្សាធម្មនុញ្ញ គឺសុំរាប់សន្លឹកឆ្នោតមិនបានការឡើងវិញ និងផ្តល់សុពលភាពឡើងវិញ ក្នុងនោះក៏មានកំណត់ហេតុដែលក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើជាមួយនាងខ្ញុំ។ អ្វីដែលនាងខ្ញុំចង់បាន គឺរាប់សន្លឹកឆ្នោតមិនបានការដើម្បីផ្តល់សុពលភាព នាងខ្ញុំមិនចង់ពិនិត្យទិន្នន័យទេ គឺចង់រាប់សន្លឹកឆ្នោតឡើងវិញ។ សុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យបញ្ហានេះឡើងវិញ។ ការដែលផ្ទៀងផ្ទាត់ទិន្នន័យសំឡេងឆ្នោត គឺផ្ទុយពីពាក្យបណ្តឹង និងកំណត់ហេតុឆ្លើយបំភ្លឺនៅក្រុមប្រឹក្សាធម្មនុញ្ញថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់នាងខ្ញុំ និងគោលដៅរបស់នាងខ្ញុំ។

លោក ហ៊ី រ៉ុង ប្រធានក្រុមត្រួតពិនិត្យ បានស្នើសុំឲ្យតំណាងគណបក្សនយោបាយគោរពតាមបទបញ្ជាផ្ទៃក្នុងដើម្បីផ្ទៀងផ្ទាត់។

ឯកឧត្តម ពិត តាំងសាន មានប្រសាសន៍ថា ក្នុងនាមក្រុមប្រឹក្សាធម្មនុញ្ញ សុំឲ្យក្រុមការងារអនុវត្តតាមនីតិវិធីរបស់ខ្លួន តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

លោកជំទាវ ចែម វេយ្យរិទ្ធ តំណាងក្រុមប្រឹក្សាធម្មនុញ្ញ មានប្រសាសន៍ថា នាងខ្ញុំមកនេះគឺអនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ឯកឧត្តម គួយ ប៊ុនរឿន តំណាងគណបក្សសង្គ្រោះជាតិ មានប្រសាសន៍ថា ទូលបង្គំមកនេះមិនមែនសុំផ្ទៀងផ្ទាត់សន្លឹកឆ្នោតឡើងវិញទេ គឺស្នើសុំឲ្យរាប់សន្លឹកឆ្នោតឡើងវិញ ដើម្បីផ្តល់សុពលភាពលើសន្លឹកឆ្នោតមិនបានការឡើងវិញ បើមិនដូច្នេះទេ គឺខុសពីគោលបំណង និងគោលដៅរបស់យើងខ្ញុំដែលបានប្តឹង និងស្នើសុំទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យសម្រេចពីតំណាងក្រុមប្រឹក្សាធម្មនុញ្ញ។

លោកជំទាវ ចែម វេយ្យរិទ្ធ តំណាងក្រុមប្រឹក្សាធម្មនុញ្ញ មានប្រសាសន៍ថា បន្ទាប់ពីតំណាងក្រុមប្រឹក្សាធម្មនុញ្ញបានពិភាក្សាគ្នា យើងខ្ញុំស្នើសុំផ្អាកដំណើរការនីតិវិធីសិន។ ប៉ុន្តែ ក្រោយពីបានពិភាក្សា និងពិចារណា និងទទួលការណែនាំពីឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ លោកជំទាវបានសម្រេចឲ្យក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់បន្តនីតិវិធីរបស់ខ្លួនឡើងវិញតទៅទៀត។

ការត្រួតពិនិត្យផ្ទៀងផ្ទាត់បានធ្វើការផ្ទៀងផ្ទាត់ម្តងមួយៗ ការិយាល័យទទួលលទ្ធផលដូចខាងក្រោម ៖

## ការិយាល័យលេខកូដ ០៧១៨

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | គ្មាន | ០១ | ០១ | |

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ២-ហ្វ៊ុនស៊ិនប៉ិច | គ្មាន | ០៩ | ០៩ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | គ្មាន | ០ | ០ | |
| ៤-ប្រជាជនកម្ពុជា | គ្មាន | ២១១ | ២១១ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | គ្មាន | ០១ | ០១ | |
| ៧-សង្គ្រោះជាតិ | គ្មាន | ៤៦ | ៤៦ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | គ្មាន | ១៣ | ១៣ | |
| សន្លឹកឆ្នោតបានការសរុប | ២៨១ | ២៨១ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ៥១ | ៥១ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៣៣២ | ៣៣២ | | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់</u> ៖

- កញ្ចប់សុវត្ថិភាព "ក" បិទជិត។

<u>កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- ផ្ទៀងផ្ទាត់ទម្រង់ ១១០២ ទម្រង់ ១១០៨ និងតារាងកត់ត្រាសំឡេងឆ្នោត។ នៅក្នុងទម្រង់ ១១០២ មានទិន្នន័យសំខាន់ៗ ហើយការអនុវត្តកន្លងមកនេះមិនគ្រប់គ្រាន់ទេ ដោយគ្រាន់តែយកចំណុចទី៥។ កន្លងមកមិនបានជម្រាបអំពីសន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ និងសន្លឹកឆ្នោតក្នុងហិប។
- ទម្រង់ ១១០២ គ្មានសរសេរទិន្នន័យ។

<u>តំណាងក្រុមប្រឹក្សាធម្មនុញ្ញ</u> ៖

លោកជំទាវ ចែម វេយ្យរិទ្ធ

- សុំឲ្យអានទិន្នន័យទាំងអស់ក្នុងទម្រង់ ១១០២ និងទម្រង់ ១១០៨ ដើម្បីលេខាកត់ត្រា។

## ការិយាល័យលេខកូដ ០២៨៣

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០៤ | ០៤ | ០៤ | |
| ២-ហ្វ៊ុនស៊ិនប៉ិច | ៣៨ | ៣៨ | ៣៨ | |

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៣ | ០៣ | ០៣ | |
| ៤-ប្រជាជនកម្ពុជា | ២៥៣ | ២៥៣ | ២៥៣ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៣ | ០៣ | ០៣ | |
| ៧-សង្គ្រោះជាតិ | ១២០ | ១២០ | ១២០ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ១៣ | ១៣ | ១៣ | |
| សន្លឹកឆ្នោតបានការសរុប | ៤៣៤ | ៤៣៤ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ៥៧ | ៥៧ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៤៩១ | ៤៩១ | | |

<u>កំណត់សម្គាល់របស់ក្រុមគ្រូតពិនិត្យ ផ្ទៀងផ្ទាត់</u> ៖

- កញ្ចប់សុវត្ថិភាព "ក" មិនមានបិទការសុវត្ថិភាព ប៉ុន្តែមានចងកៅស៊ូ។
- តារាងកត់ត្រាសំឡេងឆ្នោត មិនបានបំពេញលេខការិយាល័យ។ ក្រុមគ្រូតពិនិត្យស្នើសុំបំពេញលេខកូដការិយាល័យ។

<u>កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់សុវត្ថិភាព "ក" មិនមានបិទការសុវត្ថិភាព ប៉ុន្តែមានចងកៅស៊ូ។

## ការិយាល័យលេខកូដ ០២៨៥

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០៣ | ០៣ | ០៣ | |
| ២-ហ៊្វុនស៊ិនប៉ិច | ២០ | ២០ | ២០ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៥ | ០៥ | ០៥ | |
| ៤-ប្រជាជនកម្ពុជា | ២២១ | ២២១ | ២២១ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០២ | ០២ | ០២ | |
| ៧-សង្គ្រោះជាតិ | ១៧១ | ១៧១ | ១៧១ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ១៧ | ១៧ | ១៧ | |
| សន្លឹកឆ្នោតបានការសរុប | ៤៣៩ | ៤៣៩ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ៥៨ | ៥៨ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៤៩៧ | ៤៩៧ | | |

កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ៖

- កញ្ចប់ "ខ" មានសោឃ្លុំ និងមានលេខកូដ។
- កញ្ចប់សុវត្ថិភាព "ក" មិនមានបិទការសុវត្ថិភាព ប៉ុន្តែមានចងខ្សែរ៍។

## ការិយាល័យលេខកូដ ០៤២៥

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៤ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០៨ | ០៨ | ០៨ | |
| ២-ហ៊្វុនស៊ិនប៉ិច | ១៩ | ១៩ | ១៩ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៨ | ០៨ | ០៨ | |
| ៤-ប្រជាជនកម្ពុជា | ២១០ | ២១០ | ២១០ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០២ | ០២ | ០២ | |
| ៧-សង្គ្រោះជាតិ | ១៥៤ | ១៥៤ | ១៥៤ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ១១ | ១១ | ១១ | |
| សន្លឹកឆ្នោតបានការសរុប | ៤១២ | ៤១២ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ២០ | ២០ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៤៣២ | ៤៣២ | | |

កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ៖

- កញ្ចប់សុវត្ថិភាព "ក" បិទជិត។
- ក្រដាសកត់ត្រាសំឡេងឆ្នោត មិនបានបំពេញលេខកូដការិយាល័យ។ ក្រុមត្រួតពិនិត្យសុំបំពេញលេខកូដការិយាល័យ។

កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់ "ខ" មិនមានចាក់សោឃ្លុំ។
- ទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិបានទទួលសន្លឹកឆ្នោតបានការសរុបមានចំនួន ៤៣២ សន្លឹក ប៉ុន្តែទម្រង់ ១១០២ និងទម្រង់ ១១០៤ មានតែចំនួន ៤១២ សន្លឹក។

## ការិយាល័យលេខកូដ ០៤៤២

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៤ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០ | ០ | ០ | |
| ២-ហ៊្វុនស៊ិនប៉ិច | ១២ | ១២ | ១២ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៣ | ០៣ | ០៣ | |
| ៤-ប្រជាជនកម្ពុជា | ១៦២ | ១៦២ | ១៦២ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៣ | ០៣ | ០៣ | |
| ៧-សង្គ្រោះជាតិ | ១៤៩ | ១៤៩ | ១៤៩ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៩ | ០៩ | ០៩ | |
| សន្លឹកឆ្នោតបានការសរុប | ៣៣៨ | គ្មាន | | |
| សន្លឹកឆ្នោតមិនបានការសរុប | ២១ | គ្មាន | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៣៥៣ | គ្មាន | | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់</u> ៖

- កញ្ចប់ "ខ" មានចាក់សោឃ្លុំ។
- កញ្ចប់សុវត្ថិភាព "ក" មិនមានបិទការសុវត្ថិភាព។

<u>កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- ទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិបានទទួលសន្លឹកឆ្នោតក្នុងហិបសរុប ៣៥៩ សន្លឹក ប៉ុន្តែក្នុងទម្រង់ ១១០២ មានតែចំនួន ៣៥៣ សន្លឹក។

## ការិយាល័យលេខកូដ ០៨១៧

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៤ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០ | ០ | ០ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០៦ | ០៦ | ០៦ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០ | ០ | ០ | |
| ៤-ប្រជាជនកម្ពុជា | ១០៩ | ១០៩ | ១០៩ | |

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០២ | ០២ | ០២ | |
| ៧-សង្គ្រោះជាតិ | ២១៥ | ២១៥ | ២១៥ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៨ | ០៨ | ០៨ | |
| សន្លឹកឆ្នោតបានការសរុប | ៣៣៦ | ៣៣៦ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ០៨ | ០៨ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៣៤៤ | ៣៤៤ | | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់</u> ៖

- ក្រដាសកត់ត្រាសំឡេងឆ្នោតមិនបំពេញលេខកូដការិយាល័យ។ ក្រុមត្រួតពិនិត្យស្នើសុំបំពេញលេខកូដការិយាល័យ។
- ក្នុងទម្រង់ ១១០២ ទម្រង់ ១១០៨ មានគណបក្សប្រជាជនកម្ពុជា ០២រូប ឈ្មោះ ហឹម ណារឿង ឈ្មោះ ស៊ិន សុដាវី, គណបក្សសង្គ្រោះជាតិ ០២រូប ឈ្មោះ គើយ ដារ៉ា ឈ្មោះ សេង ពេជ្រកុល្លិកា, គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ០១រូប ឈ្មោះ ឡាច លី , គណបក្សហ៊្វុនស៊ិនប៉ិច ០១រូប ឈ្មោះ រស់ សុខា។

<u>កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់ "ខ" មិនមានចាក់សោឃ្លុំ។
- កញ្ចប់សុវត្ថិភាព "ក" មានភាពរហែក។

## ការិយាល័យលេខកូដ ០៣២៣

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០៤ | ០៤ | ០៤ | |
| ២-ហ៊្វុនស៊ិនប៉ិច | ៦៥ | ៦៥ | ៦៥ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៩ | ០៩ | ០៩ | |
| ៤-ប្រជាជនកម្ពុជា | ៣២២ | ៣២២ | ៣២២ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៨ | ០៨ | ០៨ | |

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ៧-សង្គ្រោះជាតិ | ៣០ | ៣០ | ៣០ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ១៧ | ១៧ | ១៧ | |
| សន្លឹកឆ្នោតបានការសរុប | ៨៥៥ | ៨៥៥ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ៦៩ | ៦៩ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៥២៤ | ៥២៤ | | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់</u> ៖

- ក្រដាសកត់ត្រាសំឡេងឆ្នោតមិនបានបូកសរុបតួលេខ។ ក្រុមត្រួតពិនិត្យស្នើសុំបូកសរុបក្នុងក្រដាសកត់ត្រាសំឡេងឆ្នោត។
- ទម្រង់ ១១០២ តំណាងចូលរួមចុះហត្ថលេខាមាន គណបក្សប្រជាជនកម្ពុជា ឈ្មោះ យួន ទុយ ឈ្មោះ គៀម ចៅ, គណបក្សសង្គ្រោះជាតិ ឈ្មោះ អ៊ិក ឆោង ឈ្មោះ វ៉ាត ណាន, គណបក្សហ៊្វុនស៊ិនប៉ិច ឈ្មោះ ឡៃន ស៊ាត ឈ្មោះ ឌិក ដើង។
- ទម្រង់ ១១០៨ តំណាងចូលរួមចុះហត្ថលេខាមាន គណបក្សប្រជាជនកម្ពុជា ឈ្មោះ យួន ទុយ ឈ្មោះ គៀម ចៅ, គណបក្សសង្គ្រោះជាតិ ឈ្មោះ អ៊ិក ឆោង ឈ្មោះ វ៉ាត ណាន, គណបក្សហ៊្វុនស៊ិនប៉ិច ឈ្មោះ ឡៃន ស៊ាត ឈ្មោះ ឌិក ដើង។

<u>កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់ "ខ" មិនមានចាក់សោឃ្លុំ។
- កញ្ចប់សុវត្ថិភាព "ក" មិនមានបិទការសុវត្ថិភាព និងមិនសរសេរលេខកូដការិយាល័យ។

## ការិយាល័យលេខកូដ ០៣២៤

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០៤ | ០៤ | ០៤ | |
| ២-ហ៊្វុនស៊ិនប៉ិច | ២៩ | ២៩ | ២៩ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ១០ | ១០ | ១០ | |
| ៤-ប្រជាជនកម្ពុជា | ២៩៩ | ២៩៩ | ២៩៩ | |
| [illegible] | [illegible] | [illegible] | [illegible] | |
| ៦-ខ្មែរឈប់ក្រ | ០៤ | ០៤ | ០៤ | |

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ៧-សង្គ្រោះជាតិ | ៣៣ | ៣៣ | ៣៣ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៥ | ០៥ | ០៥ | |
| សន្លឹកឆ្នោតបានការសរុប | ៣៨៤ | ៣៨៤ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ៩៩ | ៩៩ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៤៨៣ | ៤៨៣ | | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់</u> ៖

- កញ្ចប់ "ខ" មានចាក់សោឃ្លុំ និងមានលេខកូដ។
- កញ្ចប់សុវត្ថិភាព "ក" មិនមានសរសេរលេខកូដ និងមិនមានបិទការសុវត្ថិភាព។
- ក្រដាសកត់ត្រាសំឡេងឆ្នោតមិនបំពេញលេខកូដការិយាល័យ។ ក្រុមត្រួតពិនិត្យស្នើសុំបំពេញលេខកូដការិយាល័យ។
- ទម្រង់ ១១០២ តំណាងគណបក្សចូលរួមចុះហត្ថលេខាមាន គណបក្សប្រជាជនកម្ពុជា ឈ្មោះ ចាន់ ជឿន ឈ្មោះ លក ភត់, គណបក្សហ្វ៊ុនស៊ិនប៉ិច ឈ្មោះ ស៊ន់ សុត ឈ្មោះ កែប ឌិប, គណបក្សសង្គ្រោះជាតិឈ្មោះ វ៉ាន សាវី ឈ្មោះ ស៊ាប សាម៉ិក។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមចុះហត្ថលេខាមាន គណបក្សប្រជាជនកម្ពុជា ឈ្មោះ ភត់, គណបក្សសង្គ្រោះជាតិ ឈ្មោះ ស៊ាប សាម៉ិក, គណបក្សហ្វ៊ុនស៊ិនប៉ិច ឈ្មោះ កែម ឌិត។

## ការិយាល័យលេខកូដ ០៣២៦

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០៤ | ០៤ | ០៤ | |
| ២-ហ្វ៊ុនស៊ិនប៉ិច | ៣៧ | ៣៧ | ៣៧ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៣ | ០៣ | ០៣ | |
| ៤-ប្រជាជនកម្ពុជា | ១៩៧ | ១៩៧ | ១៩៧ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០២ | ០២ | ០២ | |
| ៧-សង្គ្រោះជាតិ | ៣៧ | ៣៧ | ៣៧ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ១៣ | ១៣ | ១៣ | |
| សន្លឹកឆ្នោតបានការសរុប | ២៩៣ | ២៩៣ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ១៣៧ | ១៣៧ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៤៣០ | ៤៣០ | | |

កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ៖

- កញ្ចប់ "ខ" មានចាក់សោឃ្លុំ។
- កញ្ចប់សុវត្ថិភាព "ក" មិនមានបិទការសុវត្ថិភាព។
- ក្រដាសកត់ត្រាសំឡេងឆ្នោត មិនបានសរសេរលេខកូដការិយាល័យ និងបូកសរុបតួលេខ។ ក្រុមត្រួតពិនិត្យស្នើសុំសរសេរលេខកូដការិយាល័យ និងបូកសរុបតួលេខ។
- ទម្រង់ ១១០២ តំណាងគណបក្សចូលរួមចុះហត្ថលេខាមាន គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ឈ្មោះ ថុក ធឿន, គណបក្សប្រជាជនកម្ពុជា ឈ្មោះ ហ៊ាន ណាក់, គណបក្សហ៊្វុនស៊ិនប៉ិច ឈ្មោះ យាន អាន, គណបក្សសង្គ្រោះជាតិ ឈ្មោះ មឿន ខ្មៅ។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមចុះហត្ថលេខាមាន គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ឈ្មោះ ថុក ធឿន, គណបក្សប្រជាជនកម្ពុជា ឈ្មោះ ហ៊ាន ណាក់, គណបក្សហ៊្វុនស៊ិនប៉ិច ឈ្មោះ យាន អាន, គណបក្សសង្គ្រោះជាតិ ឈ្មោះ មឿន ខ្មៅ។

## ការិយាល័យលេខកូដ ០២៩៤

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០១ | ០១ | ០១ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០៦ | ០៦ | ០៦ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០២ | ០២ | ០២ | |
| ៤-ប្រជាជនកម្ពុជា | ២២៣ | ២២៣ | ២២៣ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០១ | ០១ | ០១ | |
| ៧-សង្គ្រោះជាតិ | ៦៧ | ៦៧ | ៦៧ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៣ | ០៣ | ០៣ | |
| សន្លឹកឆ្នោតបានការសរុប | ៣០៣ | ៣០៣ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ៨០ | ៨០ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៣៨៣ | ៣៨៣ | | |

កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ៖

- កញ្ចប់ "ខ" មានចាក់សោឃ្លុំ។
- កញ្ចប់សុវត្ថិភាព "ក" មានបិទការសុវត្ថិភាព។
- ក្រដាសកត់ត្រាសំឡេងឆ្នោតមិនបំពេញលេខកូដការិយាល័យ។ ក្រុមត្រួតពិនិត្យស្នើសុំបំពេញ លេខកូដការិយាល័យ។

- ទម្រង់ ១១០២ តំណាងគណបក្សចូលរួមចុះហត្ថលេខាមាន គណបក្សប្រជាជនកម្ពុជា ឈ្មោះ អៀម រ៉ិច, គណបក្សសង្គ្រោះជាតិ ឈ្មោះ ជា ធន់។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមចុះហត្ថលេខាមាន គណបក្សប្រជាជនកម្ពុជា ឈ្មោះ អៀម រ៉ិច, គណបក្សសង្គ្រោះជាតិ ឈ្មោះ ជា ធន់។

## ការិយាល័យលេខកូដ ០៦៧៣

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០២ | ០២ | ០២ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០៣ | ០៣ | ០៣ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៣ | ០៣ | ០៣ | |
| ៤-ប្រជាជនកម្ពុជា | ២៧២ | ២៩៧ | ២៩៧ | ទម្រង់ ១១០៨ និង ក្រដាសកត់ត្រាសំឡេងឆ្នោតមានចំនួន ២៩៧ ច្រើនជាងតួលេខក្នុង ទម្រង់ ១១០២ មានតួលេខ ២៧២។ |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០១ | ០១ | ០១ | |
| ៧-សង្គ្រោះជាតិ | ៧២ | ៧២ | ៧២ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ៥២ | ៥២ | ៥២ | |
| សន្លឹកឆ្នោតបានការសរុប | ៤៣០ | ៤៣០ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ០១ | ០១ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៤៣១ | ៤៣១ | | |

កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ៖

- កញ្ចប់ "ខ" មានចាក់សោឃ្លុំ។
- កញ្ចប់សុវត្ថិភាព "ក" មានបិទការសុវត្ថិភាព។
- ក្រុមត្រួតពិនិត្យបូកសរុបជាក់ស្តែងនៅលើទម្រង់ ១១០២ សន្លឹកឆ្នោតបានការសរុបចំនួន ៤០៥។ ទម្រង់ ១១០៨ សន្លឹកឆ្នោតបានការសរុប ៤៣០សន្លឹក ដូចក្នុងទម្រង់ ១១០៨។

កំណត់សម្គាល់របស់តំណាងគណបក្សសង្គ្រោះជាតិ ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- ស្នើសុំបូកសរុបតួលេខក្នុងទម្រង់ ១១០២ និងទម្រង់ ១១០៨ ព្រោះមានតួលេខគណបក្សប្រជាជនកម្ពុជា ក្នុងទម្រង់ ១១០២ មានចំនួន ២៧២ រីឯក្នុងទម្រង់ ១១០៨ មានចំនួន ២៩៧ ហេតុអ្វីតួលេខបូកសរុបមានចំនួនស្មើគ្នា មានភាពលំអៀងសំឡេងឆ្នោតចំនួន ២៥ សំឡេង។

## ការិយាល័យលេខកូដ ០៣៤៦

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០៣ | ០៣ | ០៣ | |
| ២-ហ្វ៊ុនស៊ិនប៉ិច | ៧៨ | ៧៨ | ៧៨ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៦ | ០៦ | ០៦ | |
| ៤-ប្រជាជនកម្ពុជា | ១២៤ | ១២៤ | ១២៤ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៥ | ០៥ | ០៥ | |
| ៧-សង្គ្រោះជាតិ | ៥២ | ៥២ | ៥២ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៤ | ០៤ | ០៤ | |
| សន្លឹកឆ្នោតបានការសរុប | ២៧២ | ២៧២ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ៤២ | ៤២ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៣១៤ | ៣១៤ | | |

កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ៖

- កញ្ចប់ "ខ" មានចាក់សោឃ្លុំ។
- កញ្ចប់សុវត្ថិភាព "ក" បិទជិត។
- ទម្រង់ ១១០២ តំណាងគណបក្សចូលរួមចុះហត្ថលេខាមាន គណបក្សប្រជាជនកម្ពុជា ឈ្មោះ ពិន ប៉ុន, គណបក្សសង្គ្រោះជាតិ ឈ្មោះ តុល តាប់, គណបក្សហ្វ៊ុនស៊ិនប៉ិច ឈ្មោះ ពិន ពាត, គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ឈ្មោះ រ៉ែម រ៉ន។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមចុះហត្ថលេខាមាន គណបក្សប្រជាជនកម្ពុជា ឈ្មោះ ពិន ប៉ុន, គណបក្សសង្គ្រោះជាតិ ឈ្មោះ តុល តាប់, គណបក្សហ្វ៊ុនស៊ិនប៉ិច ឈ្មោះ ពិន ពាត, គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ឈ្មោះ រ៉ែម រ៉ន។

ការផ្ទៀងផ្ទាត់បានបញ្ចប់នៅវេលាម៉ោងដប់ និងសែសិបនាទីនាថ្ងៃខែឆ្នាំដដែល។

**តំណាងក្រុមប្រឹក្សាធម្មនុញ្ញ**

លោកជំទាវ ចែម វេយ្យរិទ្ធ..........................

ឯកឧត្តម ពិត តាំងសាន ..........................

សម្តេចព្រះមហិស្សរា នរោត្តម ច័ក្រពង្ស់..........................

**ក្រុមលេខាកត់ត្រាក្រុមប្រឹក្សាធម្មនុញ្ញ**

លោក សាយ រស្មី..........................

លោក ប៉េង សុខុម ..........................

លោកស្រី ម៉ឹង វ៉ាន់នី..........................

**តំណាងគណបក្សនយោបាយ**

**តំណាងគណបក្សសង្គ្រោះជាតិ ៖**

ឯកឧត្តម គួយ ប៊ុនរឿន..........................

លោកជំទាវ កែ សុវណ្ណរតន៍ ..........................

**តំណាងគណបក្សប្រជាជនកម្ពុជា ៖**

ឯកឧត្តម ស៊ិក ប៊ុនហុក..........................

ឯកឧត្តម កៅ សោភ័ណ្ឌ ..........................

**តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច ៖**

ឯកឧត្តម គឹម កុសល ..........................

**អង្គការសង្កេតការណ៍ជាតិ/អន្តរជាតិ**

.......................... (C.I.YA)

.......................... CDSIF

.......................... COMFREL

.......................... CCHR

..........................

..........................

..........................

..........................

**ក្រុមលេខាកត់ត្រា គ.ជ.ប**

លោក កែវ ផល្លា ..........................

លោក កែ រិទ្ធិ..........................

លោក ព្រហ្ម វិចិត្រអក្ខរា..........................

លោក ភាព វិរៈ ..........................

លោក ជោត វ៉ាន់ចាន់..........................

លោក អ៊ូ សុផុន..........................

**ក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់**

លោក ហ៊ី រ៉ុង..........................

លោក មុំ សុទ្ធ ..........................

លោក សាត់ សុវណ្ណ ..........................

លោក ហេង គួច ..........................

លោក អៀម សុង ..........................

លោក ម៉ែន សុខសុន្ទី..........................

លោក នុត យូរៀម..........................

# គណបក្សសង្គ្រោះជាតិ

# CAMBODIA NATIONAL RESCUE PARTY

## សង្គ្រោះ បម្រើ ការពារ

នាងខ្ញុំ **កែ សុវណ្ណរតន៍** ភេទស្រី អាយុ ៥១ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ៣៤CD ផ្លូវ ២៨៦ ភូមិ ១០ សង្កាត់ទូលស្វាយព្រៃ២ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០១២ ៩៣៤ ៣៥៥ តំណាងគណបក្សសង្គ្រោះជាតិខេត្តសៀមរាប ។

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល លេខ 240/044/2013
ថ្ងៃ 19 ...... ខែ 2013
ម៉ោង 8 : 18 : 20

**សូមគោរពជូន**
**ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ** ៖ ប្តឹងសុំតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប ។

**យោង** ៖ -មាត្រា ១១៥ថ្មី និងមាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ

-សម្រង់សេចក្តីសម្រេចលេខ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៣ របស់ គ.ជ.ប ដែលតំណាងគណបក្សសង្គ្រោះជាតិ បានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោ ៨:២៥ នាទី ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រធាន មេត្តាជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបានដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ មណ្ឌលខេត្តសៀមរាប ដោយហេតុថា ពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោតកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣កន្លងទៅនេះ កើតមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលមន្ត្រីបោះឆ្នោតបានបំពានច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រព្រមទាំងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ដែលជាហេតុធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ ដែលត្រូវទទួលបានក្នុងមណ្ឌលខេត្តសៀមរាប ។ ភាពមិនប្រក្រតីធ្ងន់ធ្ងរដែលខ្ញុំប្តឹងសុំទាមទារឲ្យ គ.ជ.ប ពិនិត្យ និងដោះស្រាយរកយុត្តិធម៌នោះមានបីករណី ៖

–<u>ករណីទី១</u>៖ ខ្ញុំទាមទារសុំឲ្យ គ.ជ.ប រៀបចំបោះឆ្នោតសារជាថ្មីចំនួន១៦ ការិយាល័យនៃស្រុកស្វាយលើ និងស្រុកវ៉ារិនគឺការិយាល័យលេខ ១១៣៦, ១១៥៣, ១០៥៩, ០៦៩៧, ០៦៩៥, ០៨៦៤, ១១៣៧, ១១៣៨, ១១១៦, ១០៥៧, ១១១៥, ១១៤០, ១១៤៣, ១១៧៣, ១១៤២ និង១១៧២ ដោយហេតុថាការិយាល័យទាំង១៦នេះ មានការកៀងគរទាបានដែលគ្មានទីលំនៅក្នុងឃុំ នៃស្រុក

ស្វាយលើ និងស្រុកវ៉ារិន ដោយមានការដឹកទាហានជាទ្រង់ទ្រាយធំ តាមរថយន្តធំៗ មកបោះឆ្នោតនៅការិយាល័យបោះឆ្នោតទាំងនោះ ។ ទង្វើបែបនេះ បានបំពានលើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ត្រង់ចំណុច ៧.៤.១ និង ៧.៤.៣ និងបំពានលើមាត្រា៥៤ ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ការរំលោភបំពានធ្ងន់ធ្ងរបែបនេះហើយ បែរជាមន្ត្រីការិយាល័យបោះឆ្នោតទាំង១៦ ការិយាល័យនោះ បណ្តោយឲ្យទាហានទាំងនោះបានចូលបោះឆ្នោត ។ ក្នុងរឿងនេះ ខ្ញុំមានឯកសារភស្តុតាងភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ១ ។

-<u>ករណីទី ២</u> ៖ ខ្ញុំទាមទារសុំឲ្យ គ.ជ.ប ពិនិត្យផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោត និងផ្តល់សុពលភាពលើសន្លឹកឆ្នោតមិនបានការឡើងវិញ ចំនួន២០០ ការិយាល័យ ក្នុងខេត្តសៀមរាប ។ ការិយាល័យទាំង២០០នេះ មានលេខការិយាល័យដូចមានក្នុងឯកសារឧបសម្ព័ន្ធ២ ដោយហេតុថាខ្ញុំទទួលបានព័ត៌មានពីតំណាងគណបក្ស ដែលឈរសង្កេតការណ៍នៅការិយាល័យទាំងនោះថា មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត បានរាប់លឿនពេកធ្វើឲ្យសន្លឹកឆ្នោតបានការរបស់គណបក្សសង្គ្រោះជាតិកប់នៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ដែលជាហេតុនាំឲ្យសន្លឹកឆ្នោតមិនបានការនៅតាមការិយាល័យទាំងនោះ មានចំនួនច្រើនលើសពីការិយាល័យដទៃ ។ ចំពោះតំណាងគណបក្សសង្គ្រោះជាតិដែលសង្កេតការណ៍នៅការិយាល័យទាំងនោះ បានចុះហត្ថលេខាលើទម្រង់១១០២ មិនមែនមានន័យថាយល់ព្រមទទួលស្គាល់លើលទ្ធផលនៃការបោះឆ្នោត រឺទទួលស្គាល់ថាមិនមានភាពមិនប្រក្រតីនៅក្នុងការិយាល័យបោះឆ្នោតទាំងនោះទេ។ បើគ្រាន់តែតំណាងគណបក្សនយោបាយចុះហត្ថលេខាលើកំណត់ហេតុរាប់សន្លឹកឆ្នោតទម្រង់ ១១០២ ចាត់ទុកជាការទទួលស្គាល់លទ្ធផលបោះឆ្នោត រឺ ទទួលស្គាល់ថាមិនមានភាពមិនប្រក្រតីនៅក្នុងការិយាល័យបោះឆ្នោតយកជាបានការរួចទៅហើយនោះ មិនចាំបាច់ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមាត្រា ១១៤ ទុកសិទ្ធិឲ្យគណបក្សនយោបាយប្តឹងតវ៉ាលើលទ្ធផលបោះឆ្នោតបណ្តោះអាសន្ននោះទេ។

-<u>ករណីទី៣</u> ៖ ខ្ញុំទាមទារសុំឲ្យ គ.ជ.បបើកកញ្ចប់សុវត្ថិភាព"ក" ដកយកទម្រង់ ១១០២ និង ១១០៨ ដើម្បីពិនិត្យផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតជាមួយ ទម្រង់ ១១០៤ ដោយសារតួលេខក្នុងទម្រង់ ១១០៤ ដែលស្រង់ចេញពី ១១០២ ពុំមានទិន្នន័យគ្រប់គ្រាន់។ ករណីនេះ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ គ.ជ.ប បានអនុញ្ញាតឲ្យផ្ទៀងផ្ទាត់ទម្រង់១១០២ និង១១០៤ នៅក្រៅកញ្ចប់សុវត្ថិភាព"ក" ហើយបានឃើញមានភាពមិនប្រក្រតីធ្ងន់ធ្ងរដោយទម្រង់ ១១០៤ ឯកសារដើមនៅ គ.ជ.ប មានបំពេញទិន្នន័យតួលេខពេញ រីឯទម្រង់ ១១០៤ ផ្តល់ជូនគណបក្សនយោបាយដែលភ្ជាប់ការបោនពីខាងក្រោម បែរជាមានទិន្នន័យតួលេខមិនពេញលេញទៅវិញ។ ម្យ៉ាងទៀត ឯកសារទម្រង់ ១១០៤ដើមខ្លះ នៅលើដៃខ្ញុំមានទិន្នន័យតួលេខមិនពេញលេញ បែរជាឯកសារទម្រង់ ១១០៤ ដែលភ្ជាប់កាបោនពីក្រោមនៅខាង គ.ជ.ប មានទិន្នន័យតួលេខពេញលេញទៅវិញ។

ភាពមិនប្រក្រតីធ្ងន់ធ្ងរទាំងបីករណីខាងលើនេះ បានធ្វើឲ្យប៉ះពាល់លទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ នៅមណ្ឌលខេត្តសៀមរាប ធ្ងន់ធ្ងរខ្លាំងណាស់ តែបែរជា គ.ជ.ប សម្រេចសេចក្តីទាំងបំពានច្បាប់ និងបទបញ្ជា និងនីតិវិធី បដិសេធពាក្យបណ្តឹងរបស់ខ្ញុំចោលដោយស្ងាត់ៗមិនបើក

សវនាការជាសាធារណៈ ដើម្បីដោះស្រាយបណ្តឹងឲ្យស្របតាមមាត្រា ១១៤ និង ១១៦ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីបញ្ជាក់ពីតម្លាភាព ដើម្បីឲ្យអ្នកឈ្នះ ឈ្នះដោយកិត្តិយស និងអ្នកចាញ់ ចាញ់ដោយអស់ចិត្ត។ ក្នុងរឿងនេះខ្ញុំសូមធ្វើសំណូមពរដូចខាងក្រោម ៖

<u>សំណូមពរ៖</u> សុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប ចោលជាអាសារបង់ ហើយខ្ញុំស្នើសុំទាមទារឲ្យក្រុមប្រឹក្សាធម្មនុញ្ញមេត្តាចេញសេចក្តីសម្រេច ៖

១-បង្គាប់ឲ្យ គ.ជ.ប រៀបចំការបោះឆ្នោតសាជាថ្មីចំនួន១៦ការិយាល័យ នៅស្រុកស្វាយលើ និងស្រុកវ៉ារិន ដូចមានបញ្ជាក់លេខការិយាល័យខាងលើស្រាប់ ស្របតាមមាត្រា១១៤ និង១១៦ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

២-បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព"ក" ពិនិត្យរាប់សន្លឹកឆ្នោត និងផ្តល់សុពលភាពលើសន្លឹកឆ្នោតមិនបានការឡើងវិញចំនួន២០០ការិយាល័យក្នុងមណ្ឌលខេត្តសៀមរាប ដែលការិយាល័យទាំងនោះដូចមានបញ្ជាក់ក្នុងឯកសារឧបសម្ព័ន្ធ២ ។

៣-បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព"ក" យកទម្រង់ ១១០២ និង១១០៨ មកផ្ទៀងផ្ទាត់លទ្ធផលជាមួយទម្រង់១១០៤ ចំនួន៧៥ ការិយាល័យ ដូចមានឯកសារបញ្ជាក់មកជាមួយក្នុងឧបសម្ព័ន្ធ៣ និងសុំឲ្យផ្តល់សុពលភាពលទ្ធផលបោះឆ្នោតតាមការិយាល័យនីមួយៗឡើងវិញ បើមានការប្រែប្រួលតួលេខក្រោយពេលពិនិត្យផ្ទៀងផ្ទាត់។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមឯកឧត្តមប្រធានមេត្តាផ្តល់នូវភាពយុត្តិធម៌ដល់គណបក្សសង្គ្រោះជាតិតាមការស្នើសុំខាងលើទៅតាមផ្លូវច្បាប់ ។

សូមឯកឧត្តមប្រធាន ទទួលនូវការគោរពដោយស្មោះពីនាងខ្ញុំ ៕

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

**ស្នាមមេដៃស្តាំ**



**កែ សុវណ្ណរតន៍**

សូមជូនភ្ជាប់មកជាមួយនូវ ៖

- លិខិតលេខ ០២២/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)
- ពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៣ របស់លោកជំទាវ កែ សុវណ្ណរតន៍ (សំណុំរឿងលេខ ០៩៨/១៣ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៣)
- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៣៩/០៤៣/២០១៣

ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៤៣/០១៨/២០១៣ កបធ.ច

ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

អាគារសវិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញសេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **អេង ឆៃអ៊ាង** តំណាងគណបក្សសង្គ្រោះជាតិ ប្តឹងសុំតវ៉ានឹងសម្រេចសេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ពាក្យសុំកែតម្រូវពាក្យបណ្តឹងរបស់ឯកឧត្តម **អេង ឆៃអ៊ាង** ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ស្នើសុំកែតម្រូវលើពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ផ្ទេរសិទ្ធិជូនឯកឧត្តម **អេង ឆៃអ៊ាង** ជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ មណ្ឌលខេត្តកណ្តាល
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៨៨/១៣ គ.ជ.ប ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **អេង ឆៃអ៊ាង** កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០១៣ អមដោយសារណាការពារ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ចំនួនបីទំព័រ
- បានឃើញសេចក្តីសម្រេចលេខ ៣១/២០១៣ កបធ.សសរ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព " ក " មួយចំនួននៅមណ្ឌលខេត្តកណ្តាល នៅក្រុងតាខ្មៅ សង្កាត់តាខ្មៅ
- បានឃើញលិខិតលេខ ០៤៨/២០១៣ កបធ.ច ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ ចាត់តាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ៣រូបដើម្បីចូលរួមស្រាវជ្រាវ ស៊ើបអង្កេតការបើកកញ្ចប់សុវត្ថិភាព " ក " នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " មួយចំនួននៅមណ្ឌលខេត្តកណ្តាល ដើម្បីផ្ទៀងផ្ទាត់សន្លឹកឆ្នោត ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៩០៧/១៣ គ.ជ.ប ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣
- បានឃើញលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ឯកឧត្តម **អេង ឆៃអ៊ាង** ប្រគល់សិទ្ធិជូនលោកមេធាវី **ជូង ជូងី** ដើម្បីការពារនូវសិទ្ធិ និងផលប្រយោជន៍

ស្របច្បាប់របស់គណបក្សសង្គ្រោះជាតិ នៅចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងសំណុំរឿងលេខ ២៣៩/០៤៣/២០១៣ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

- បានឃើញលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ របស់ឯកឧត្តម **អេង ឆៃអ៊ាង** ប្រគល់សិទ្ធិជូនលោកមេធាវី **កែត ឃី** ដើម្បីការពារនូវសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់គណបក្សសង្គ្រោះជាតិ នៅចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងសំណុំរឿងលេខ ២៣៩/០៤៣/២០១៣ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣
- បានឃើញលិខិតតំណាងដោយអាណត្តិ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **ជូង ជូងី** និងពាក្យសុំតំណាងដោយអាណត្តិចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **កែត ឃី**
- បានឃើញសេចក្តីសម្រេចលេខ ០៥៤/២០១៣ កបធ.ច ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **អេង ឆៃអ៊ាង** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី១៩ ខែសីហាឆ្នាំ២០១៣ វេលាម៉ោង១៣ និង ៥០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ថ្មី និងមាត្រា១១៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២នៃមាត្រា២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន
- យល់ឃើញថា តាមខ្លឹមសារនៃបណ្តឹងរបស់ឯកឧត្តម **អេង ឆៃអ៊ាង** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ គឺប្តឹងសុំតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ឯកឧត្តម **អេង ឆៃអ៊ាង** បានរៀបរាប់ថា នៅមណ្ឌលបោះឆ្នោតខេត្តកណ្តាល មានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលមន្ត្រីរៀបចំការបោះឆ្នោតបានរំលោភបំពានច្បាប់បោះឆ្នោត និង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ ដែលត្រូវទទួលបានក្នុងមណ្ឌលខេត្តកណ្តាល។ ភាពមិនប្រក្រតីធ្ងន់ធ្ងរនោះមានបីករណី ៖ ១-នៅថ្ងៃបោះ

ឆ្នោត ទី២៨ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោងប្រមាណ ៩ ព្រឹក ការិយាល័យលេខ ១២០៤ ឃុំស្ពានថ្ម ត្រូវបានបិទរហូត ដោយសារការកើតមានអសន្តិសុខ ហើយការបោះឆ្នោតទើបតែបោះឆ្នោតបាន ប្រមាណ ៨០ នាក់ នៅសល់ប្រមាណជិត ២០០នាក់ទៀត មិនបានបោះឆ្នោត ។ ម៉្យាងទៀត ហិប ឆ្នោតនៅការិយាល័យលេខ ១២០៤ នេះ ត្រូវបានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល បើកហិបរាប់សន្លឹកឆ្នោតជាឯកតោភាគី ដោយមិនបានអញ្ជើញតំណាងគណបក្ស អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ មកចូលរួមពិនិត្យនោះឡើយ ។ ២-ឯកឧត្តមបានដាក់ពាក្យបណ្តឹងនៅគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ទាមទារសុំឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្ទៀងផ្ទាត់ទម្រង់ ១១០២ និង១១០៨ ដែលស្ថិតនៅក្នុងកញ្ចប់សុវត្ថិភាព "ក" ចំនួន ១៩៩ ការិយាល័យ ។ បន្ទាប់ពីបានផ្ទៀងផ្ទាត់ ជាបន្តបន្ទាប់តាមឃុំ សង្កាត់ បានចំនួន ១៩១ ការិយាល័យ លុះនៅសល់តែសង្កាត់តាខ្មៅ មាន ០៨ ការិយាល័យ បែរជាគ្មានទម្រង់ ១១០៨ មកពិនិត្យផ្ទៀងផ្ទាត់ ។ ៣- ឯកឧត្តម សុំបើកកញ្ចប់សុវត្ថិ ភាព" ក " ដើម្បីយកសន្លឹកឆ្នោតមិនបានការទាំង ៧២ ការិយាល័យមកពិនិត្យផ្ទៀងផ្ទាត់ ដោយហេតុថា តំណាងគណបក្សសង្គ្រោះជាតិនៅមូលដ្ឋានបានផ្តល់ព័ត៌មានថា មន្ត្រីរាប់សន្លឹកឆ្នោតនៅការិយាល័យ រាប់សន្លឹកឆ្នោតទាំងនោះ រាប់លឿនពេក និង មានការបន្លំសន្លឹកឆ្នោតបានការ នាំឱ្យសន្លឹកឆ្នោតបានការ របស់គណបក្សសង្គ្រោះជាតិ ត្រូវបានគេដាក់ចូលទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ។ ដើមបណ្តឹង ឆ្លើយនឹងសំណួររបស់ក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញថា នៅក្នុងថ្ងៃបោះឆ្នោតទី២៨ ខែកក្កដា ឆ្នាំ២០១៣ ពុំឃើញមានការបាញ់គ្នាទេ ប៉ុន្តែឯកឧត្តមបានដឹងថា មានការចាប់មនុស្សនៅឃុំស្ពានថ្ម ចំនួន ០១នាក់ ហើយនៅឃុំសារិកាកែវចំនួន ០២ នាក់ ប៉ុន្តែនៅវេលាល្ងាចត្រូវបានដោះលែងវិញ ។ នៅក្នុងពេលបោះឆ្នោត ការបោះឆ្នោតបានប្រព្រឹត្តទៅដោយសម្ងាត់ ។ ដើមបណ្តឹងបានសំណូមពរសុំឱ្យ ក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយសុំទាមទារឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ចេញសេចក្តីសម្រេច ÷ ១-បង្គាប់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រៀបចំការបោះឆ្នោត សាជាថ្មីនៅការិយាល័យលេខ ១២០៤ ឃុំស្ពានថ្ម ស្របតាមមាត្រា ១១៦ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ ២- បង្គាប់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិ-ភាព " ក " ដើម្បីយកទម្រង់ ១១០២ និង ១១០៨ ធ្វើការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោត ចំនួន ០៨ ការិយាល័យ នៅសង្កាត់តាខ្មៅ គឺការិយាល័យលេខ ១០៦៨ ១០៧១ ០៨៣៣ ១១៨១ ១១៥៦ ១២៣៨ ១២៩១ និង ១២៩២ ដែលបាត់ទម្រង់ ១១០៨ ហើយត្រូវផ្តល់សុពលភាព លើលទ្ធផលបោះឆ្នោតតាមការិយាល័យនីមួយៗ បើរកឃើញមានការប្រែប្រួល ៣-បង្គាប់ឱ្យ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បើកកញ្ចប់សុវត្ថិភាព" ក " ដើម្បីយកសន្លឹកឆ្នោតមិនបានការ ទាំង ៧២ ការិយាល័យមកពិនិត្យផ្ទៀងផ្ទាត់ និង ផ្តល់សុពលភាពលើសន្លឹកឆ្នោតមិនបានការឡើងវិញ

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ឯកឧត្តម **អេង ឆៃអ៊ាង** អមដោយ លោកមេធាវី **កែត ឃី** តំណាងដោយអាណត្តិ បានអរគុណដល់ក្រុមប្រឹក្សាធម្មនុញ្ញដែលបានបើក សវនាការជាសាធារណៈ និងបានរៀបរាប់ឡើងវិញនូវខ្លឹមសារដែលមានចែងនៅក្នុងពាក្យបណ្តឹង និង ខ្លឹមសារដែលឯកឧត្តមបានឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ហើយលើកពីអង្គហេតុ និង អង្គច្បាប់ដើម្បីដាក់បន្ទុកលើគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ។ ជាចុងក្រោយដើមបណ្តឹងបានសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះ មេត្តាផ្តល់ យុត្តិធម៌ដល់គណបក្សសង្គ្រោះជាតិ ។ ឯកឧត្តម **អេង ឆៃអ៊ាង**បាននិយាយបន្ថែមថា សវនាការបីលើក កន្លងមកនៅក្រុមប្រឹក្សាធម្មនុញ្ញធ្វើគ្រាន់តែល្អមើល។ សវនាការលើកនេះ គាត់និយាយថា គាត់ស្ទើរតែដឹង លទ្ធផលជាមុន ។ ឯកឧត្តម **អេង ឆៃអ៊ាង** បានសុំអត់ទោសចំពោះក្រុមប្រឹក្សាជំនុំជម្រះថា មិនអាច នៅបន្តដល់ចុងបញ្ចប់នៃសវនាការបានទេ ។ ដើមបណ្តឹង និង លោកមេធាវី **កែត ឃី** តំណាងដោយ អាណត្តិ បានបោះបង់ការចូលរួមក្នុងសវនាការជាសាធារណៈវេលាម៉ោង ០៨ និង៤០នាទី
- យល់ឃើញថា ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅពេល ឆ្លើយបំភ្លឺចំពោះមុខក្រុមទី១នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ អមដោយ សារណាការពារចំនួនបីទំព័រ ក៏ដូចជានៅពេលសវនាការជំនុំជម្រះជាសាធារណៈបានបញ្ជាក់ថា ៖ ១-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចមិនធ្វើការបោះឆ្នោតសាជាថ្មី នៅការិយាល័យ លេខ ១២០៤ ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ដោយសំអាងថា គណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោត មិនបានបិទការិយាល័យបោះឆ្នោតនេះទេ តែការិយាល័យបោះឆ្នោតនេះ ត្រូវបានរាំងខ្ទាន ដោយជនមួយក្រុមនិងសកម្មជនរបស់គណបក្សសង្គ្រោះជាតិ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនព្រមបិទការិយាល័យនេះ ពីព្រោះការិយាល័យនេះ មានចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីតែ ២៥៨ នាក់ ហើយពលរដ្ឋបានបោះរួច ចំនួន ៨៨ នាក់។ ម៉្យាងវិញទៀត ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺខេត្តជាមណ្ឌលបោះឆ្នោត មិនមែនការិយាល័យទេ ហើយខេត្តកណ្តាលនេះមានប្រជាពលរដ្ឋ ទៅបោះឆ្នោតបានចំនួនរហូតដល់៧៧,៨៣ភាគរយ គឺច្រើនជាងរាជធានី និងខេត្តដទៃទៀតទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែខេត្តតាកែវបាន ៧៨,៤១ ភាគរយ និង ខេត្តកែបបាន ៧៧,៨៨ភាគរយ ។ បើគិតភាគរយចំនួនអ្នកបានបោះឆ្នោតនៅឃុំស្អាងភ្នំ គឺបានរហូតដល់៧៨,៣១ ភាគរយ។ ចំពោះការបើកហិបឆ្នោត ដើម្បីរាប់សន្លឹកឆ្នោតគឺ ធ្វើឡើងនៅទីស្នាក់ការគណៈកម្មការ រៀបចំការបោះឆ្នោតខេត្តកណ្តាល តាមការអនុញ្ញាតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងដោយមានការចូលរួមពីតំណាងគណបក្សប្រជាជនកម្ពុជា អ្នកសង្កេតការណ៍មកពីអង្គការខុមហ្វ្រែល អង្គការសហគមន៍គ្រួសារអភិវឌ្ឍន៍កសិកម្ម លើកលែងតែតំណាងគណបក្សសង្គ្រោះជាតិដែលមិនព្រម ចូលរួម តាមការអញ្ជើញ **២**-ចំពោះការប្តឹងតវ៉ាសុំផ្ទៀងផ្ទាត់ទម្រង់ ១១០២ និង ១១០៨ ចំនួន ១៥៩ ការិយាល័យ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចយល់ព្រមផ្ទៀងផ្ទាត់ទម្រង់ ១១០២

និង ១១០៨ ដោយសារគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានទម្រង់ ១១០២ និង ១១០៨ ដែលប្រមូលបានពីតាមខេត្ត ហើយទម្រង់នេះ និងទម្រង់ ១១០២ និង ១១០៨ នៅខាងក្នុងកញ្ចប់សុវត្ថិភាព "ក" មានតួលេខទិន្នន័យដូចគ្នា ហើយសុទ្ធតែមានចុះហត្ថលេខារបស់តំណាងគណបក្សនយោបាយផងដែរ ។ ចំពោះការិយាល័យចំនួន ០៨ នៅក្នុងសង្កាត់តាខ្មៅ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគ្មានទម្រង់ ១១០៨ ដោយសារគណៈកម្មការរៀបចំការបោះឆ្នោតសង្កាត់តាខ្មៅ បានធ្វើឱ្យបាត់ ប៉ុន្តែ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានយកទម្រង់ ១១០៩ ជំនួសវិញ ដោយសារទម្រង់នេះ បានស្រង់ទិន្នន័យចេញពីទម្រង់ ១១០២ និងទម្រង់ ១១០៨។ ការត្រួតពិនិត្យបង្ហាញថា លទ្ធផលត្រឹមត្រូវដដែល ៣- ចំពោះករណីសុំរាប់សន្លឹកឆ្នោតមិនបានការក្នុង៧២ការិយាល័យ ឯកឧត្តម **អេង ឆៃអ៊ាង** ពុំបានផ្តល់ភស្តុតាងច្បាស់លាស់ ដូចមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺអ្នកប្តឹងត្រូវផ្តល់ឯកសារ ភស្តុតាង និង សាក្សី បញ្ជាក់ថា គណៈកម្មការរាប់សន្លឹកឆ្នោតបានប្រព្រឹត្តខុសទៅនឹងបទបញ្ជា និងនីតិវិធីនៃការរាប់សន្លឹកឆ្នោត ។ ម្យ៉ាងវិញទៀតទម្រង់ ១១០២ មិនបានបញ្ជាក់ពីភាពមិនប្រក្រតី ឬមានការតវ៉ាក្នុងពេលរាប់សន្លឹកឆ្នោតនោះទេ ហើយទម្រង់នេះ ក៏បានបិទផ្សាយជាសាធារណៈនៅគ្រប់ការិយាល័យរាប់សន្លឹកឆ្នោតរួចហើយ ។ ប៉ុន្តែនៅពេលនេះ ដើមបណ្តឹងគ្រាន់តែបង្ហាញអំពីការគិតរបស់ខ្លួន តាមតួលេខក្នុងទម្រង់ ១១០៤ ដែលគាត់មានតែប៉ុណ្ណោះ ។ សរុបសេចក្តីមក បណ្តឹងនេះ ត្រូវបានបដិសេធតាមមាត្រា ១១៥ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ប៉ុន្តែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចេញសេចក្តីសម្រេចតាមការធ្វើសវនាការសង្ខេប ដោយសារគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានយល់ព្រមធ្វើការត្រួតពិនិត្យដោះស្រាយជាសាធារណៈនូវចំណុចទី២ ជូនដើមបណ្តឹង ស្របតាមមាត្រា ១១៦ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់នេះ ។ ជាចុងក្រោយ ឯកឧត្តម **មាន សាទិ** សំណូមពរសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញមេត្តារក្សាសេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការ

- យល់ឃើញថា ពេលបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ០៨ ការិយាល័យនៅសង្កាត់តាខ្មៅ នាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមសេចក្តីសម្រេចលេខ ៣១/២០១៣ កបធ.ច ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ បានបង្ហាញឱ្យឃើញថា កញ្ចប់ "ឃ" ទាំងពីរមិនមានសោឃ្លុំ កញ្ចប់ " គ " ទាំងប្រាំមួយមានសោឃ្លុំ កញ្ចប់សុវត្ថិភាព "ក" ទាំងប្រាំបីការិយាល័យមានបិទភ្ជិតដោយការសុវត្ថិភាពត្រូវតាមលក្ខណៈបច្ចេកទេស ។ ចំពោះតួលេខលទ្ធផលនៃសំឡេងឆ្នោតដែលគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា ក៏ដូចជាគណបក្សនយោបាយនានាទទួលបានមានទិន្នន័យដូចគ្នា រវាងទម្រង់ ១១០២ ប្រៀបនឹងទម្រង់១១០៨ ជាមួយនឹងផ្ទាំងក្រដាសធំសម្រាប់កត់ត្រាសំឡេងឆ្នោត ។ ជាសំខាន់ គឺតួលេខលទ្ធផលទាំងអស់នៅ

ដដែល ពុំមានប្រែប្រួលអ្វីឡើយ ។ សូមអានឧបសម្ព័ន្ធស្តីពីកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាព"ក" មួយចំនួន នៅមណ្ឌលខេត្តកណ្តាល

- យល់ឃើញថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកណ្តាលសរុបមានចំនួន ១.៤៤០ ការិយាល័យ ការបោះឆ្នោតពុំមានជួបករណីប្រធានស័ក្តិ ពុំមានករណីអសន្តិសុខ និងពុំមានអំពើហិង្សាទេ ។ ប្រជាពលរដ្ឋបានបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៧៧,៨៣ ភាគរយ
- យល់ឃើញថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

### ករណីបណ្តឹងជំទាស់ ចំពោះមុខតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់ឯកឧត្តម **អេង ឆៃអ៊ាង** ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

**ឧបសម្ព័ន្ធនៃសេចក្តីសម្រេច**
**លេខ១៤៣/០១៨/២០១៣ គបធ.ច**
**ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ
# ស្តីពី
# ការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួន នៅមណ្ឌលខេត្តកណ្តាល ដើម្បីផ្ទៀងផ្ទាត់សន្លឹកឆ្នោត

- យោងសេចក្តីសម្រេចលេខ ៣១/២០១៣ កបធ.សសរ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ។
- យោងលិខិតបង្គាប់ការលេខ ៨៧៨/១៣ គ.ជ.ប ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ឆ្នាំពីរពាន់ដប់បី ខែកញ្ញា ថ្ងៃអាទិត្យ ទីមួយ វេលាម៉ោងប្រាំពីរ និងសែសិបនាទីព្រឹក នៅសាលសន្និសីទនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តកណ្តាល នៅក្រុងតាខ្មៅ សង្កាត់តាខ្មៅ ការិយាល័យបោះឆ្នោតលេខ ១០៦៨ ១០៧១ ០៨៣៣ ១១៨១ ១១៥៦ ១២៣៨ ១២៩១ និង ១២៩២ សរុបមាន ០៨ការិយាល័យបោះឆ្នោត ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោតក្នុងទម្រង់ ១១០២ ១១០៨ និងក្រដាសធំកត់ត្រាសំឡេងឆ្នោត ក្រោមការត្រួតពិនិត្យរបស់ក្រុមស៊ើបអង្កេតក្រុមប្រឹក្សាធម្មនុញ្ញ។

ឯកឧត្តម អ៊ិត ឈន បានមានប្រសាសន៍ថា តំណាងក្រុមប្រឹក្សាធម្មនុញ្ញថ្ងៃនេះ មាន ០៣រូប សម្តេចនរោត្តម សិរីវុឌ្ឍ, ឯកឧត្តម អ៊ិត ឈន, ឯកឧត្តម ពិត តាំងសាន ដើម្បីស៊ើបអង្កេតលើដំណើរការនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់។ ជាកិច្ចបន្ទាប់ឯកឧត្តម បានអានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ៣១/២០១៣ កបធ.សសរ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ ស្តីពីការអនុញ្ញាតឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តកណ្តាល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់នេះ បានឃើញច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់នេះ បានឃើញបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ សម្រេច ប្រការ ១ អនុញ្ញាតឲ្យគណៈកម្មាធិការជាតិរៀបចំបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តកណ្តាល នៅក្រុងតាខ្មៅ សង្កាត់តាខ្មៅ ការិយាល័យលេខ ១០៦៨ ១០៧១ ០៨៣៣ ១១៨១ ១១៥៦ ១២៣៨ ១២៩១ និង ១២៩២ សរុបមាន ០៨ការិយាល័យ ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោតក្នុងទម្រង់ ១១០២ ១១០៨ និងក្រដាសធំកត់ត្រាសំឡេងឆ្នោត។ ប្រការ ២ ការបើកកញ្ចប់សុវត្ថិភាព "ក" ខាងលើត្រូវធ្វើនៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនាថ្ងៃអាទិត្យ ទី១ ខែកញ្ញា ឆ្នាំ២០១៣ វេលា

ម៉ោង ៨:០០ព្រឹក។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបំពេញភារកិច្ចស្របតាមច្បាប់កំណត់ និងធ្វើកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាពខាងលើនេះ។ ប្រការ ៣ ក្រុមប្រឹក្សាធម្មនុញ្ញ នឹងចាត់តាំងតំណាងឲ្យទៅចូលរួមស្រាវជ្រាវស៊ើបអង្កេត ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣។

លោក មុំ សុទ្ធ ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ និងជាអនុប្រធានក្រុមត្រួតពិនិត្យនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានជម្រាបអំពីនីតិវិធីនៃការអនុវត្តបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ០៨ ការិយាល័យ នៃខេត្តកណ្តាល មានដូចតទៅ ទី១.ការបង្ហាញកញ្ចប់សុវត្ថិភាព "ក", ទី២.ការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីដកយកទម្រង់ ១១០២ ១១០៨ និងក្រដាសធំកត់ត្រាសំឡេងឆ្នោត, ទី៣.ការអានសំឡេងឆ្នោតគណបក្សនយោបាយទទួលបានតាមទម្រង់នីមួយៗ ដើម្បីកត់ត្រា, ទី៤.ការបិទផ្សាយទម្រង់ទាំង០៣ នៅលើក្តារខៀន, ទី៥. ការថតចម្លងទម្រង់ ១១០២ ១១០៨ ដើម្បីចែកជូនគណបក្សនយោបាយ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ។ ការបើកកញ្ចប់សុវត្ថិភាពនេះ ធ្វើឡើងម្តងមួយកញ្ចប់ៗ រហូតដល់អស់ទាំង ០៨កញ្ចប់។ មុននឹងចាប់ផ្តើមអនុវត្ត ខ្ញុំសូមអនុញ្ញាតជម្រាបជូនសមាជិក សមាជិកា អង្គពិធីទាំងមូលសូមមេត្តាគោរពឲ្យបានត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុង។ ចំពោះការចោទសួរនូវសំណួរផ្សេងៗ ត្រូវសុំការអនុញ្ញាតពីតំណាងក្រុមប្រឹក្សាធម្មនុញ្ញជាមុន និងសូមប្រើពាក្យពេចន៍ឲ្យបានសមគួរក្នុងអង្គពិធី និងសូមប្រគល់ភារកិច្ចជូនក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ដើម្បីអនុវត្ត។

ឯកឧត្តម គួយ ប៊ុនរឿន តំណាងគណបក្សសង្គ្រោះជាតិ បានមានប្រសាសន៍ថា សូមក្រាបថ្វាយបង្គំសម្តេច ឯកឧត្តម តំណាងក្រុមប្រឹក្សាធម្មនុញ្ញ យោងតាមសេចក្តីលេខ ៣១/២០១៣ កបធ.សសរ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ ចុះហត្ថលេខាដោយឯកឧត្តម ឯក សំអុល នៅត្រង់ប្រការ ២ បានប្រគល់ភារកិច្ចឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អនុវត្តតាមនីតិវិធី និងច្បាប់កំណត់។ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានសម្រេចបែបនេះ ប៉ុន្តែអ្វីដែលគណបក្សសង្គ្រោះជាតិកត់សម្គាល់ គឺនៅក្នុងពាក្យបណ្តឹងរបស់តំណាងគណបក្សសង្គ្រោះជាតិ បានប្តឹងនោះ គឺទី១.ស្នើសុំឲ្យមានការបោះឆ្នោតឡើងវិញការិយាល័យ ១២០៤, ទី២ ស្នើសុំឲ្យធ្វើការផ្ទៀងផ្ទាត់ចំនួន ០៨ការិយាល័យ នៅទម្រង់ ១១០២ ១១០៨ និងក្រដាសធំកត់ត្រាសំឡេងឆ្នោត, ទី៣ ស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ និងផ្ទៀងផ្ទាត់ចំនួន ៧២ការិយាល័យនៃសន្លឹកឆ្នោតមិនបានការដើម្បីផ្តល់សុពលភាពឡើងវិញ ដូច្នេះ ការសម្រេចឲ្យបើកកញ្ចប់សុវត្ថិភាព "ក" តែ ០៨ការិយាល័យមិនគ្រប់គ្រាន់ និងស្នើសុំឲ្យមានការដោះស្រាយតាមពាក្យបណ្តឹង។ អំពីនីតិវិធីនៃការផ្ទៀងផ្ទាត់ ដោយសារក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អនុវត្ត និងគោរពឲ្យបានពេញលេញក្នុងសេចក្តីសម្រេចនេះ ដូច្នេះខ្ញុំស្នើសុំឯកឧត្តមតំណាងក្រុមប្រឹក្សាធម្មនុញ្ញ បញ្ជាទៅក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ឲ្យអនុវត្តតួនាទីរបស់ខ្លួនឲ្យស្របទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចតទៅ ទី១.ក្រុមត្រួតពិនិត្យត្រូវបញ្ជាក់ថា កញ្ចប់សុវត្ថិភាព "ឃ" ដែលត្រូវកាត់

យកកញ្ចប់ "ក" តើមានសោឃ្លុំ និងលេខកូដដែរ ឬទេ?, ទី២. ពេលបើកកញ្ចប់ "ក" ទូលបង្គំខ្ញុំ ស្នើសុំឲ្យអនុវត្ត ពេញលេញដោយអានទិន្នន័យទាំងអស់នៅក្នុងទម្រង់។ ទូលបង្គំខ្ញុំស្នើសុំឲ្យអនុវត្តតាមរបៀបនេះ។

លោក អ៊ុក ស៊ុយ តំណាងគណបក្សសង្គ្រោះជាតិ បានមានប្រសាសន៍ថា ទូលបង្គំខ្ញុំស្នើសុំបំពេញបន្ថែម ដោយសារឃើញលោក មុំ សុទ្ធ បានប្រកាសឲ្យអនុវត្តបន្តតាមនីតិវិធីត្រួតពិនិត្យរដ្ឋបាល នេះជាលើកទី១ហើយ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អនុវត្តតាមនីតិវិធីរដ្ឋបាល ប៉ុន្តែក្នុងពេលនេះ ខ្ញុំសូមអនុញ្ញាតជម្រាបជូន សម្តេចឯកឧត្តមថា កញ្ចប់ "ឃ" នេះ មិនមានសោឃ្លុំសុវត្ថិភាពទេ។ ដូច្នេះ ទូលបង្គំស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញធ្វើការពិចារណាក្នុងករណីនេះឲ្យបានត្រឹមត្រូវផង មុននឹងអនុវត្តនីតិវិធីបន្តទៀត សូមឲ្យលេខាធិការកត់ត្រាសរសេរក្នុងកំណត់ហេតុបញ្ជាក់ឲ្យបានច្បាស់ថា កញ្ចប់សុវត្ថិភាព "ឃ" ពិតជាគ្មានសោឃ្លុំ។

ឯកឧត្តម អ៊ុត ឈន តំណាងក្រុមប្រឹក្សាធម្មនុញ្ញ បានមានប្រសាសន៍ ទូលបង្គំខ្ញុំស្នើសុំឲ្យក្រុមលេខាកត់ត្រានូវការលើកឡើងរបស់តំណាងគណបក្សសង្គ្រោះជាតិចូលក្នុងកំណត់ហេតុរបស់ក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់។

ឯកឧត្តម គួយ ប៊ុនរឿន តំណាងគណបក្សសង្គ្រោះជាតិ បានមានប្រសាសន៍ ទូលបង្គំខ្ញុំស្នើសុំឲ្យមានកត់ត្រាអំពីមិនបានយកកំណត់ហេតុនៃការប្រគល់ទទួលកញ្ចប់ និងការបិទសោសុវត្ថិភាព មកធ្វើការផ្ទៀងផ្ទាត់មុនពេលបើកកញ្ចប់សុវត្ថិភាព "ឃ"។

ឯកឧត្តម អ៊ុត ឈន តំណាងក្រុមប្រឹក្សាធម្មនុញ្ញ បានមានប្រសាសន៍ ឲ្យក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវអនុវត្តតាមនីតិវិធី ហើយក្រុមលេខាធ្វើការកត់ត្រា និងបង្ហាញបានច្បាស់ និងបានឮដល់អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងតំណាងគណបក្សនយោបាយ ។

ជាកិច្ចចាប់ផ្តើម ក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់បានអនុវត្តនីតិវិធីរបស់ខ្លួន ដោយបានបង្ហាញកញ្ចប់ "ឃ" ចំនួន ០២ ឃើញថា កញ្ចប់ "ឃ" នីមួយៗអត់មានចាក់សោឃ្លុំបិទជិត។ ក្រុមត្រួតពិនិត្យបានដកយកចេញកញ្ចប់ "គ" ចំនួន ០៦ ដែលកញ្ចប់នីមួយៗសុទ្ធតែមានសោឃ្លុំ។ ក្រុមត្រួតពិនិត្យបានកាត់ផ្តាច់សោឃ្លុំកញ្ចប់ "គ"ទាំង ០៦ ម្តងមួយៗដើម្បីយកចេញនូវកញ្ចប់ "ខ" ពាក់ព័ន្ធដែលមានផ្ទុកនូវកញ្ចប់សុវត្ថិភាព "ក" ចំនួន ០៨ នៅការិយាល័យលេខ ១០៦៨ ១០៧១ ០៨៣៣ ១១៨១ ១១៥៦ ១២៣៨ ១២៩១ និង ១២៩២។

ឯកឧត្តម អេង ឆៃអ៊ាង ជាដើមបណ្តឹង និងជាតំណាងគណបក្សសង្គ្រោះជាតិ បានមានប្រសាសន៍ថា ដោយកញ្ចប់ "ឃ" ក៏ដូចជាកញ្ចប់ "គ" និងកញ្ចប់ "ខ" មួយចំនួន ដែលគណៈកម្មការត្រួតពិនិត្យផ្ទៀងផ្ទាត់បានកាត់ មិនមានកំណត់ហេតុបង្ហាញ ទូលបង្គំខ្ញុំ ស្នើសុំឲ្យលេខាកត់ត្រាចូលក្នុងកំណត់ហេតុឲ្យបានច្បាស់លាស់ ដោយនៅពេលកាត់សោឃ្លុំ ក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ មិនបានយកកំណត់ហេតុមកបង្ហាញតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងអ្នកសារព័ត៌មាន។

ឯកឧត្តម អ៊ុត ឈន តំណាងក្រុមប្រឹក្សាធម្មនុញ្ញ បានមានប្រសាសន៍ថា លេខាធិការកត់ត្រា ត្រូវកត់ត្រាក្នុងកំណត់ហេតុរបស់ខ្លួន តាមការស្នើសុំរបស់ដើមបណ្តឹង ដែលជាតំណាងគណបក្សសង្គ្រោះជាតិ ថា ពេលកាត់សោឃ្លុំ ក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់មិនបានយកកំណត់ហេតុមកបង្ហាញ ហើយឯកឧត្តម ក៏បាន

បញ្ជាឲ្យក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ មុននឹងចាប់ផ្តើម ត្រួតពិនិត្យផ្ទៀងផ្ទាត់ ត្រូវសួរក្រុមការងាររបស់ខ្លួនថា ត្រៀមហើយ ឬនៅ បើរួចហើយបន្តនីតិវិធីអនុវត្ត។

ការត្រួតពិនិត្យផ្ទៀងផ្ទាត់បានចាប់ផ្តើមធ្វើការផ្ទៀងផ្ទាត់ម្តងមួយការិយាល័យៗ ទទួលលទ្ធផល ដូចខាងក្រោម ៖

## ការិយាល័យលេខកូដ ១០៦៨

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០១ | ០១ | ០១ | |
| ២-ហ្វ៊ុនស៊ិនប៉ិច | ០២ | ០២ | ០២ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០១ | ០១ | ០១ | |
| ៤-ប្រជាជនកម្ពុជា | ២៤៣ | ២៤៣ | ២៤៣ | |
| ៥-ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច | ០ | ០ | ០ | |
| ៦-ខ្មែរឈប់ក្រ | ០១ | ០១ | ០១ | |
| ៧-សង្គ្រោះជាតិ | ២៨០ | ២៨០ | ២៨០ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៤ | ០៤ | ០៤ | |
| សន្លឹកឆ្នោតបានការសរុប | ៥៣២ | ៥៣២ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ០៥ | ០៥ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៥៣៧ | ៥៣៧ | | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់</u> ៖

- កញ្ចប់ "ខ" មានចងខ្សែ។
- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាពជិត។
- ទម្រង់ ១១០២ តំណាងគណបក្សចូលរួមហត្ថលេខា រួមមាន ឈ្មោះ ហ៊ិន សុខឿន គណបក្សហ្វ៊ុនស៊ិនប៉ិច, ឈ្មោះ សេង ឆេងលីម គណបក្ស សបបបក, ឈ្មោះ អ៊ិន ពិសី សបបបក, ឈ្មោះ ជា ណារ័ត្ន គណបក្សសង្គ្រោះជាតិ, ឈ្មោះ ពុធ សុត អង្គការខុមហ្វ្រែល។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមហត្ថលេខា រួមមានឈ្មោះ ហ៊ិន សុខឿន គណបក្សហ្វ៊ុនស៊ិនប៉ិច, ឈ្មោះ សេង ឆេងលីម គណបក្ស សបបបក, ឈ្មោះ អ៊ិន ពិសី សបបបក, ឈ្មោះ ជា ណារ័ត្ន គណបក្សសង្គ្រោះជាតិ, ឈ្មោះ ពុធ សុត អង្គការខុមហ្វ្រែល។

<u>កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

**ឯកឧត្តម គួយ ប៊ុនរឿន ៖**

- កញ្ចប់ "ខ" មិនមានចាក់សោឃ្លុំ ខុសនីតិវិធី។

- ស្នើសុំអនុវត្តឲ្យពេញលេញ ដោយសារទម្រង់ ១១០៥ ដែលគណបក្សសង្គ្រោះជាតិបាន ទទួល មិនមានតួលេខពេញលេញទេ។

<u>តំណាងក្រុមប្រឹក្សាធម្មនុញ្ញ</u> ៖

ឯកឧត្តម អ៊ឹក ឈនះ

- សុំឲ្យក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ បន្តការងាររបស់ខ្លួនតទៅទៀត ដោយសារក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ បានអានរួចហើយ។

## ការិយាល័យលេខកូដ ១០៧១

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០ | ០ | ០ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០៧ | ០៧ | ០៧ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០ | ០ | ០ | |
| ៤-ប្រជាជនកម្ពុជា | ២៣៤ | ២៣៤ | ២៣៤ | |
| ៥-ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ០១ | ០១ | ០១ | |
| ៦-ខ្មែរឈប់ក្រ | ០២ | ០២ | ០២ | |
| ៧-សង្គ្រោះជាតិ | ២៥៨ | ២៥៨ | ២៥៨ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៦ | ០៦ | ០៦ | |
| សន្លឹកឆ្នោតបានការសរុប | ៥០៨ | ៥០៨ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ០៣ | ០៣ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៥១១ | ៥១១ | | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់</u> ៖

- កញ្ចប់ "ខ" មានចងខ្សែ។
- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាពជិត។
- ទម្រង់ ១១០២ តំណាងគណបក្សចូលរួមហត្ថលេខា រួមមាន ឈ្មោះ រុន ចាន់រី គណបក្សសង្គ្រោះជាតិ, ឈ្មោះ ឯម បូរម្យ គណបកក្សប្រជាជនកម្ពុជា។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមហត្ថលេខា រួមមាន ឈ្មោះ រុន ចាន់រី គណបក្សសង្គ្រោះជាតិ, ឈ្មោះ ឯម បូរម្យ គណបកក្សប្រជាជនកម្ពុជា។

<u>កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់ "ខ" មិនមានចាក់សោឃ្លុំ។
- ស្នើសុំ ទម្រង់ ១១០៤ ដែលបានទទួលមិនបានកត់ត្រាពេញលេញ។ មានលក្ខណពិសេស គឺមានសន្លឹកឆ្នោតយកទៅប្រើប្រាស់ប៉ុន្មាន។ សុំឲ្យក្រុមត្រួតពិនិត្យអាន ថាតើសន្លឹកឆ្នោត បានទទួលប៉ុន្មាន នៅសល់ប៉ុន្មាន។

តំណាងក្រុមប្រឹក្សាធម្មនុញ្ញ ៖

ឯកឧត្តម អ៊ុត ឈន ៖

- សុំលេខាកត់ត្រាសំណើ។ តំណាងគណបក្សនយោបាយអាចទៅកត់ត្រានៅក្តារខៀន ព្រោះ ក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ បានយកទៅបិទរួចហើយ។

## ការិយាល័យលេខកូដ ០៨៣៣

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រា សំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០ | ០ | ០ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០១ | ០១ | ០១ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០ | ០ | ០ | |
| ៤-ប្រជាជនកម្ពុជា | ១៩៨ | ១៩៨ | ១៩៨ | |
| ៥-ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ០ | ០ | ០ | |
| ៦-ខ្មែរឈប់ក្រ | ០ | ០ | ០ | |
| ៧-សង្គ្រោះជាតិ | ៣០៨ | ៣០៨ | ៣០៨ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៦ | ០៦ | ០៦ | |
| សន្លឹកឆ្នោតបានការសរុប | ៥១៣ | ៥១៣ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ០៣ | ០៣ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៥១៦ | ៥១៦ | | |

កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ៖

- កញ្ចប់ "ខ" មានចងខ្សែ។
- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាពជិត។
- ទម្រង់ ១១០២ តំណាងគណបក្សចូលរួមហត្ថលេខា រួមមាន ឈ្មោះ សិក សំអាត គណបក្សប្រជាជនកម្ពុជា, ឈ្មោះ មៅ ផល គណបក្សហ៊្វុនស៊ិនប៉ិច, ឈ្មោះ អ៊ុំ ស្រីមុំ គណបក្សសង្គ្រោះជាតិ។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមហត្ថលេខា រួមមាន ឈ្មោះ សិក សំអាត គណបក្សប្រជាជនកម្ពុជា, ឈ្មោះ មៅ ផល គណបក្សហ៊្វុនស៊ិនប៉ិច, ឈ្មោះ អ៊ុំ ស្រីមុំ គណបក្ស

សង្គ្រោះជាតិ។

កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- សុំឲ្យក្រុមគ្រូតពិនិត្យប្រកាសថា កញ្ចប់ "ខ" អត់មានចាក់សោឃ្លុំ។

តំណាងក្រុមប្រឹក្សាធម្មនុញ្ញ ៖

ឯកឧត្តម អ៊ិត ឈន ៖

- យល់ព្រមតាមសំណើ ក្រុមគ្រូតពិនិត្យអនុវត្តការកិច្ច។

## ការិយាល័យលេខកូដ ១១៨១

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | | ០ | ០ | |
| ២-ហ៊្វុនស៊ិនប៉ិច | | ០១ | ០១ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | | ០ | ០ | |
| ៤-ប្រជាជនកម្ពុជា | | ១៦៥ | ១៦៥ | |
| ៥-ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច | | ០ | ០ | |
| ៦-ខ្មែរឈប់ក្រ | | ០១ | ០១ | ក្រដាសកត់ត្រាសំឡេងឆ្នោតមិនបានបូកសរុប។ ក្រុមប្រឹក្សាធម្មនុញ្ញអនុញ្ញាតឲ្យក្រុមគ្រូតពិនិត្យបូក។ |
| ៧-សង្គ្រោះជាតិ | | ៣៥០ | ៣៥០ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | | ០៤ | ០៤ | |
| សន្លឹកឆ្នោតបានការសេរុប | | ៥២១ | | |
| សន្លឹកឆ្នោតមិនបានការសេរុប | | ០៤ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | | ៥២៥ | | |

កំណត់សម្គាល់របស់ក្រុមគ្រូតពិនិត្យ ផ្ទៀងផ្ទាត់ ៖

- កញ្ចប់ "ខ" មានចងខ្សែ។
- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាពជិត។
- ក្នុងកញ្ចប់សុវត្ថិភាព "ក" ទម្រង់ ១១០២ មិនមានទេ មានតែទម្រង់ ១១០១ ពីរច្បាប់។
- ក្រដាសកត់ត្រាគូសសំឡេងឆ្នោត ០១ សំឡេង ប៉ុន្តែខ្ទង់សរុបកត់ត្រា ០សំឡេងទៅវិញ។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមហត្ថលេខា រួមមាន ឈ្មោះ ឌុន សុគន្ធី គណបក្ស

ប្រជាជនកម្ពុជា, ឈ្មោះ ឧន ណាក់ឌី គណបក្សហ៊្វុនស៊ិនប៉ិច, ឈ្មោះ ញឹម សុខញាន គណបក្សសង្គ្រោះជាតិ។

កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- ស្នើសុំឲ្យក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ ប្រកាសកញ្ចប់ "ខ" មិនមានចាក់សោឃ្លុំ។
- តាមសេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញ តម្រូវឲ្យយក ១១០២ ១១០៨ និងក្រដាសធំ ដូច្នេះខុសនីតិវិធីទៅហើយ ចំពោះការិយាល័យនេះ មិនអាចបន្តទៅទៀតបានទេ។

ក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ ៖

លោក ហ៊ី វ៉ុង ៖

- តាមនីតិវិធី កញ្ចប់ "ខ" មិនតម្រូវឲ្យ ចាក់សោឃ្លុំទេ។

តំណាងក្រុមប្រឹក្សាធម្មនុញ្ញ ៖

ឯកឧត្តម អ៊ិត ឈន ៖

- លេខាកត់ត្រាត្រូវកត់ត្រាក្នុងកំណត់ហេតុ ហើយបន្តនីតិវិធីជាបន្តទៀត។
- ក្រុមប្រឹក្សាធម្មនុញ្ញអនុញ្ញាតឲ្យកែតម្រូវសំឡេងឆ្នោតគណបក្សខ្មែរឈប់ក្រក្នុងក្រដាសកត់ត្រាពី ០ សំឡេង ទៅ ០១ សំឡេងវិញ ដោយចុះហត្ថលេខាក្រុមត្រួតពិនិត្យ និងបិចហ្វីតពណ៌ផ្សេង។

## ការិយាល័យលេខកូដ ១១៥៦

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០១ | ០១ | ០១ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០១ | ០១ | ០១ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០២ | ០២ | ០២ | |
| ៤-ប្រជាជនកម្ពុជា | ២២៧ | ២២៧ | ២២៧ | |
| ៥-ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ០ | ០ | ០ | |
| ៦-ខ្មែរឈប់ក្រ | ០២ | ០២ | ០២ | |
| ៧-សង្គ្រោះជាតិ | ២៦៤ | ២៦៤ | ២៦៤ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៥ | ០៥ | ០៥ | |
| សន្លឹកឆ្នោតបានការសរុប | ៥០២ | ៥០២ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ០៧ | ០៧ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៥០៩ | ៥០៩ | | |

<u>កំណត់សម្គាល់របស់ក្រុមគ្រូតពិនិត្យ ផ្ទៀងផ្ទាត់</u> ៖

- កញ្ចប់ "ខ" មានចងខ្សែ។
- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាពជិត។
- ទម្រង់ ១១០២ តំណាងគណបក្សចូលរួមចុះហត្ថលេខា រួមមាន ឈ្មោះ ជួប ស្រីនាង គណបក្សសង្គ្រោះជាតិ, ឈ្មោះ ឡុង សារ៉ាត អង្គការខុមហ្វ្រែល, ឈ្មោះ ញឹក សារុធ គណបក្សសង្គ្រោះជាតិ, ឈ្មោះ តាំង ពិសិដ្ឋ គណបក្សប្រជាជនកម្ពុជា, ឈ្មោះ គង់ យ៉ាន់ គណបក្សប្រជាជនកម្ពុជា, ឈ្មោះ ចាន់ ចំរើន គណបក្សហ៊្វុនស៊ិនប៉ិច។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមចុះហត្ថលេខា រួមមាន ឈ្មោះ ជួប ស្រីនាង គណបក្សសង្គ្រោះជាតិ, ឈ្មោះ ឡុង សារ៉ាត អង្គការខុមហ្វ្រែល, ឈ្មោះ ញឹក សារុធ គណបក្សសង្គ្រោះជាតិ, ឈ្មោះ តាំង ពិសិដ្ឋ គណបក្សប្រជាជនកម្ពុជា, ឈ្មោះ គង់ យ៉ាន់ គណបក្សប្រជាជនកម្ពុជា, ឈ្មោះ ចាន់ ចំរើន គណបក្សហ៊្វុនស៊ិនប៉ិច។

<u>កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់ "ខ" មិនមានចាក់សោឃ្លុំ។

## ការិយាល័យលេខកូដ ១២៣៨

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០ | ០ | ០ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០១ | ០១ | ០១ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០ | ០ | ០ | |
| ៤-ប្រជាជនកម្ពុជា | ១៦៩ | ១៦៩ | ១៦៩ | |
| ៥-ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ០១ | ០១ | ០១ | |
| ៦-ខ្មែរឈប់ក្រ | ០១ | ០១ | ០១ | |
| ៧-សង្គ្រោះជាតិ | ២៧៤ | ២៧៤ | ២៧៤ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៤ | ០៤ | ០៤ | |
| សន្លឹកឆ្នោតបានការសរុប | ៤៥០ | ៤៥០ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ០៩ | ០៩ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៤៥៩ | ៤៥៩ | | |

<u>កំណត់សម្គាល់របស់ក្រុមគ្រូតពិនិត្យ ផ្ទៀងផ្ទាត់</u> ៖

- កញ្ចប់ "ខ" មានចងខ្សែ។

- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាពជិត។
- ទម្រង់ ១១០២ តំណាងគណបក្សចូលរួមចុះហត្ថលេខា រួមមាន ឈ្មោះ រ៉ា ណាឫទ្ធិ គណបក្សប្រជាជនកម្ពុជា, ឈ្មោះ ឡុង ច័ន្ទដារិទ្ធ គណបក្សសង្គ្រោះជាតិ។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមចុះហត្ថលេខា រួមមាន ឈ្មោះ រ៉ា ណាឫទ្ធិ គណបក្សប្រជាជនកម្ពុជា, ឈ្មោះ ឡុង ច័ន្ទដារិទ្ធ គណបក្សសង្គ្រោះជាតិ។

កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់ "ខ" មិនមានចាក់សោឃ្លុំ។

## ការិយាល័យលេខកូដ ១២៩១

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០១ | ០១ | ០១ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០១ | ០១ | ០១ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០១ | ០១ | ០១ | |
| ៤-ប្រជាជនកម្ពុជា | ១៩៣ | ១៩៣ | ១៩៣ | |
| ៥-ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ០ | ០ | ០ | |
| ៦-ខ្មែរឈប់ក្រ | ០ | ០ | ០ | |
| ៧-សង្គ្រោះជាតិ | ២៤៦ | ២៤៦ | ២៤៦ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៤ | ០៤ | ០៤ | |
| សន្លឹកឆ្នោតបានការសរុប | ៤៤៦ | ៤៤៦ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ០១ | ០១ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៤៤៧ | ៤៤៧ | | |

កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ៖

- កញ្ចប់ "ខ" មានចងខ្សែ។
- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាពជិត។
- ទម្រង់ ១១០២ តំណាងគណបក្សចូលរួមចុះហត្ថលេខា រួមមាន ឈ្មោះ សេក រតនាធិតា គណបក្សហ៊្វុនស៊ិនប៉ិច, ឈ្មោះ នេត ឡូន គណបក្សប្រជាជនកម្ពុជា, ឈ្មោះ អ៊ឹង ឧត្តមលក្ខណ៍ គណបក្សសង្គ្រោះជាតិ។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមចុះហត្ថលេខា រួមមាន ឈ្មោះ សេក រតនាធិតា គណបក្សហ៊្វុនស៊ិនប៉ិច, ឈ្មោះ នេត ឡូន គណបក្សប្រជាជនកម្ពុជា, ឈ្មោះ អ៊ឹង ឧត្តមលក្ខណ៍

គណបក្សសង្គ្រោះជាតិ។

<u>កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់ "ខ" មិនមានចាក់សោឃ្លុំ។

## ការិយាល័យលេខកូដ ១២៩២

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០១ | ០១ | ០១ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០៣ | ០៣ | ០៣ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០ | ០ | ០ | |
| ៤-ប្រជាជនកម្ពុជា | ១៧៩ | ១៧៩ | ១៧៩ | |
| ៥-ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ០ | ០ | ០ | |
| ៦-ខ្មែរឈប់ក្រ | ០ | ០ | ០ | |
| ៧-សង្គ្រោះជាតិ | ១៩៧ | ១៩៧ | ១៩៧ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៥ | ០៥ | ០៥ | |
| សន្លឹកឆ្នោតបានការសរុប | ៣៨៥ | ៣៨៥ | | |
| សន្លឹកឆ្នោតមិនបានការសរុប | ០១ | ០១ | | |
| សន្លឹកឆ្នោតក្នុងហិបសរុប | ៣៨៦ | ៣៨៦ | | |

<u>កំណត់សម្គាល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់</u> ៖

- កញ្ចប់ "ខ" មានចងខ្សែ។
- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាពជិត។
- ទម្រង់ ១១០២ តំណាងគណបក្សចូលរួមចុះហត្ថលេខា រួមមាន ឈ្មោះ អ៊ុំ សំខាន់ពិសុទ្ធ គណបក្សសង្គ្រោះជាតិ, ឈ្មោះ ឌី ចាន់ធឿន គណ បក្សប្រជាជនកម្ពុជា, ឈ្មោះ ហ៊ុល សុខមាក គណបក្សហ៊្វុនស៊ិនប៉ិច។
- ទម្រង់ ១១០៨ តំណាងគណបក្សចូលរួមចុះហត្ថលេខា រួមមាន ឈ្មោះ អ៊ុំ សំខាន់ពិសុទ្ធ គណបក្សសង្គ្រោះជាតិ, ឈ្មោះ ឌី ចាន់ធឿន គណបក្សប្រជាជនកម្ពុជា, ឈ្មោះ ហ៊ុល សុខមាក គណបក្សហ៊្វុនស៊ិនប៉ិច។

<u>កំណត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់ "ខ" មិនមានចាក់សោឃ្លុំ។

ការផ្ទៀងផ្ទាត់បានបញ្ចប់នៅវេលាម៉ោងដប់ និងម្ភៃនាទីនាថ្ងៃខែឆ្នាំដដែល។

**តំណាងក្រុមប្រឹក្សាធម្មនុញ្ញ**

សម្តេច នរោត្តម សិរិវុឌ្ឍ ..............................

ឯកឧត្តម អ៊ិត ឈន ..............................

ឯកឧត្តម ពិត តាំងសាន ..............................

**ក្រុមលេខាកត់ត្រាក្រុមប្រឹក្សាធម្មនុញ្ញ**

ឯកឧត្តម យុន សំណាង ..............................

លោក យន់ សំណាង ..............................

លោក ថូ ឧត្តម ..............................

**តំណាងគណបក្សនយោបាយ**

**តំណាងគណបក្សសង្គ្រោះជាតិ ៖**

ឯកឧត្តម គួយ ប៊ុនរឿន ..............................

ឯកឧត្តម អេង ឆៃអ៊ាង ..............................

លោក អ៊ុក ស៊ុយ ..............................

**តំណាងគណបក្សប្រជាជនកម្ពុជា ៖**

ឯកឧត្តម ព្រុំ សុខា ..............................

ឯកឧត្តម ស៊ុក ប៊ុនហុក ..............................

**តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច ៖**

លោក យារ បូរ៉ា ..............................

**អង្គការសង្កេតការណ៍ជាតិ/អន្តរជាតិ**

.............................. (VIYA)

.............................. CCHR

.............................. (COMFREL)

.............................. COSIF

..............................

..............................

..............................

**ក្រុមលេខាកត់ត្រា គ.ជ.ប**

លោក កែវ ផល្លា ..............................

លោក កែ រិទ្ធិ ..............................

លោក ព្រហ្ម វិចិត្រអក្ខរា ..............................

លោក ភាព វិរៈ ..............................

លោក ជោត វ៉ាន់ចាន់ ..............................

លោក អ៊ូ សុផុន ..............................

**ក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់**

លោក ហ៊ឺ វ៉ុង ..............................

លោក មុំ សុទ្ធ ..............................

លោក សាត់ សុវណ្ណ ..............................

លោក ហេង គុច ..............................

លោក អៀម សុង ..............................

លោក ម៉ែន សុខសុន្ទី ..............................

លោក នុត យូរៀម ..............................

# គណបក្សសង្គ្រោះជាតិ
# CAMBODIA NATIONAL RESCUE PARTY

**សង្គ្រោះ បម្រើ ការពារ**

## ពាក្យសុំកែតំរូវពាក្យបណ្ដឹង

ខ្ញុំ **អេង ឆៃអ៊ាង** ភេទប្រុស អាយុ ៤៨ឆ្នាំ សញ្ជាតិ ខ្មែរ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ១៦ A ផ្លូវ ៣៤៨ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០១៧ ២០៣ ៣៣៣ ជាតំណាងគណបក្ស សង្គ្រោះជាតិ ខេត្តកណ្ដាល។

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ..............
ថ្ងៃ 23 សីហា 2013
ម៉ោង 11:10

**សូមគោរពជូន**

**ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ** : ស្នើសុំកែតំរូវលើពាក្យបណ្តឹង ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ខ្ញុំបាទដែលបានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៣ និង ៥០នាទី

តបតាមកម្មវត្ថុខាងលើនេះ ខ្ញុំសូមជំរាបជូន ឯកឧត្តមប្រធាន មេត្តាជ្រាបថា កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបានដាក់ពាក្យបណ្តឹង ប្តឹងតវ៉ានឹងសម្រេចសេចក្តីសម្រេច លេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ មានកំហុសមួយចំនួនក្នុងការវាយកុំព្យូទ័រ ដូច្នេះ ខ្ញុំសុំធ្វើការកែតម្រូវលើពាក្យបណ្តឹងរបស់ខ្ញុំនូវចំនុចដូចខាងក្រោម :

-ត្រង់ចំនុច "យោង មាត្រា ១៥ថ្មី" កែ ទៅជា "មាត្រា ១១៥ថ្មី"។

-ត្រង់ "ទំព័រទី២ ចំនុច ករណីទី២" និង "ត្រង់ទំព័រទី៤ ចំនុចសំណូមពរទី២" ដែលសរសេរថា "៨ ការិយាល័យ គឺ ការិយាល័យលេខ ១០៦៨ ១០៧១ ១១៨១ ១១៥៦ ១២៣៨ ១២៩១ និង ១២៩២" កែ មកជា "៨ ការិយាល័យ គឺការិយាល័យលេខ ១០៦៨ ១០៧១ ០៨៣៣ ១១៨១ ១១៥៦ ១២៣៨ ១២៩១ និង ១២៩២"។

អាស្រ័យដូចបានស្នើសុំកែតម្រូវខាងលើនេះ សូមឯកឧត្តមប្រធាន មេត្តាពិនិត្យនិងសំរួលតាមការស្នើសុំដោយអនុគ្រោះ។

សូមឯកឧត្តមប្រធានមេត្តាទទួលនូវការគោរពដ៏ស្មោះ អំពីខ្ញុំ។

*ភ្នំពេញ* ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣

**អេង ឆៃអ៊ាង**

ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House #576, National Road N°2, Sangkat Chakangres Leu, Khan Mean Chey Phnom Penh, Kingdom of Cambodia
Tel : 012 90 57 75 / 092 92 51 71

# គណបក្សសង្គ្រោះជាតិ

# CAMBODIA NATIONAL RESCUE PARTY

**សង្គ្រោះ បម្រើ ការពារ**

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ ៤៦៧/០៤៣/២០១៣
ថ្ងៃ ១៩ សីហា ២០១៣
ម៉ោង ៤ ១៣:៥០

## ពាក្យបណ្តឹង

ខ្ញុំ អេង ឆៃអ៊ាង ភេទប្រុស អាយុ៤៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ១៦A ផ្លូវ៣៤៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០១៧ ២០៣ ៣៣៣ និងជាតំណាងគណបក្សសង្គ្រោះជាតិខេត្តកណ្តាល ។

**សូមគោរពជូន**
**ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ** ៖ ប្តឹងសុំតវ៉ានឹងសម្រេចសេចក្តីសម្រេចលេខ០២១/១៣ គ.ជ.ប.ស.សរ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប។

**យោង** ៖ -មាត្រា១៥ថ្មី និងមាត្រា១១៧ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។
-សម្រង់សេចក្តីសម្រេចលេខ០២១/១៣ គ.ជ.ប.ស.សរ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប ដែលតំណាងគណបក្សសង្គ្រោះជាតិ បានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ០៨:២៥ នាទីព្រឹក។

តាមកម្មវត្ថុ និងយោងខាងលើនេះ ខ្ញុំសូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបានដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ មណ្ឌលខេត្តកណ្តាល ដោយហេតុថា ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ កន្លងមកនេះ កើតមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលមន្ត្រីរៀបចំការបោះឆ្នោតបានរំលោភបំពានច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ ដែលត្រូវទទួលបានក្នុងមណ្ឌលខេត្តកណ្តាល។ ភាពមិនប្រក្រតីធ្ងន់ធ្ងរដែលខ្ញុំប្តឹងទាមទារឲ្យ គ.ជ.ប ពិនិត្យ និងដោះស្រាយរកយុត្តិធម៌នោះមានបីករណីគឺ ៖

*<u>**ករណីទី១**</u> ៖ ខ្ញុំទាមទារសុំឲ្យ គ.ជ.ប រៀបចំបោះឆ្នោតសារជាថ្មីនៅការិយាល័យលេខ១២០៤ នៅក្នុងឃុំស្អាងភ្នំ ដោយហេតុថា នៅថ្ងៃបោះឆ្នោតទី២៨ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោងប្រមាណ៩ ការិយាល័យលេខ១២០៤នេះ ត្រូវបានបិទរហូតដោយសារការកើតមានអសន្តិសុខ ហើយការបោះឆ្នោត ទើបតែបោះឆ្នោតបានប្រមាណ៨០នាក់ នៅសល់ប្រមាណជិត២០០នាក់ទៀត មិនបានបោះឆ្នោត។ ម្យ៉ាងទៀតហិបឆ្នោតនៅការិយាល័យលេខ១២០៤នោះ គណៈកម្មការខេត្តកណ្តាលរៀបចំការបោះឆ្នោត (គ.ខ.ប) បានយកមកបើកហិបរាប់សន្លឹកឆ្នោតជាឯកតោភាគី ដោយមិនបានអញ្ជើញតំណាងគណបក្ស អ្នកសង្កេតការណ៍ជាតិ-អន្តរជាតិ មកចូលរួមពិនិត្យនោះឡើយ។ ក្នុងរឿងនេះខ្ញុំមានសាក្សីដឹងលឺ និង ឃើញហេតុការណ៍ដោយផ្ទាល់៖

ទី១-ឈ្មោះ **យី សុខសាន្ត** ភេទប្រុស ទូរស័ព្ទលេខ ០១២ ៨៨៣ ៩៨៩ និង ០១៦ ៨៣៥ ៥៩៧

ទី២-ឈ្មោះ **តាត់ សាម្ងន** ភេទប្រុស ទូរស័ព្ទលេខ ០១២ ៥៩០ ៧២៥

ទង្វើនិងសកម្មភាពខុសឆ្គងរបស់មន្ត្រីរៀបចំការបោះឆ្នោតខេត្តកណ្តាល បានបំពានលើបទបញ្ញា នីតិវិធីសម្រាប់ការបោះឆ្នោតនីតិកាលទី៥ ត្រង់ចំណុច៨.៧.២៦,៨.៩.៩, ៨.៩.៦.១, ៨.៩.៦.៤ និងមាត្រា ១១១ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ការបំពានពីសំណាក់មន្ត្រីរៀបចំការ បោះឆ្នោតខេត្តកណ្តាលនេះ គឺជាភាពមិនប្រក្រតីដែលធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់លទ្ធផល នៃការបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ ក្នុងការិយាល័យលេខ១២០៤ នៅឃុំស្អាងភ្នំ។

*<u>**ករណីទី២**</u> ៖ ខ្ញុំទាមទារសុំឲ្យ គ.ជ.ប ផ្ទៀងផ្ទាត់ទម្រង់១១០២ និង១១០៨ ដែលស្ថិតនៅក្នុង កញ្ចប់សុវត្ថិភាព "ក" ចំនួន១៩៩ការិយាល័យ ដោយហេតុថា ប្រធានការិយាល័យទាំង១៩៩នោះ (មាន រៀបរាប់ក្នុងឧបសម្ព័ន្ធ១) មិនបានកត់ត្រាបញ្ចូលទិន្នន័យតួលេខក្នុងទម្រង់១១០៨ ដែលខ្ញុំទទួលបាន ដោយទម្រង់១១០៨នោះ មានលក្ខណៈមិនពេញលេញ ដោយមិនបញ្ចូលទិន្នន័យត្រង់ចំនុចទី២ និយាយ ពីលទ្ធផលនៃការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត តាមការិយាល័យបោះឆ្នោតដោយពុំបានដាក់តួលេខ ក្នុងចំនុច ក.ខ.គ.ឃ.ង (ឯកសារភស្តុតាងទាំង១៩៩ ការិយាល័យ បានផ្តល់ជូន គ.ជ.ប រួចហើយ) ។ ការសុំទាមទារនេះ គ.ជ.ប មិនបានផ្ទៀងផ្ទាត់ទម្រង់១១០៨ និង១១០២ដែលយកចេញពីកញ្ចប់ សុវត្ថិភាព "ក" តាមការស្នើសុំរបស់ខ្ញុំនោះទេ តែ គ.ជ.ប បែរជាយកទម្រង់១១០៨ និង១១០២ដែល នៅក្រៅកញ្ចប់សុវត្ថិភាព "ក" មកពិនិត្យផ្ទៀងផ្ទាត់ទៅវិញ។ នៅពេលពិនិត្យផ្ទៀងផ្ទាត់ មន្ត្រី គ.ជ.ប បានយកទម្រង់១១០៨ និង១១០២ក្រៅកញ្ចប់នោះ មកផ្ទៀងផ្ទាត់ជាបន្តបន្ទាប់តាមឃុំ/សង្កាត់ នីមួយៗ។ លុះនៅសល់តែមួយសង្កាត់ចុងក្រោយគឺសង្កាត់តាខ្មៅមាន៨ការិយាល័យគឺ ការិយាល័យ លេខ១០៦៨, ១០៧១, ១១៨១, ១១៥៦, ១២៣៨, ១២៩១ និង១២៩២ បែរជាគ្មានទម្រង់១១០៨ យក មកពិនិត្យផ្ទៀងផ្ទាត់នោះទេ លុះដល់ពេលខ្ញុំសួររកទម្រង់១១០៨ មន្ត្រី គ.ជ.ប ឆ្លើយថាគ្មានទេ មាននៅ សល់តែក្នុងកញ្ចប់សុវត្ថិភាព "ក" ពេលនោះខ្ញុំក៏សុំទាមទារឲ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីយក ទម្រង់១១០៨ ទាំង៨ការិយាល័យនោះ មកធ្វើការពិនិត្យផ្ទៀងផ្ទាត់ តែមន្ត្រី គ.ជ.ប ឆ្លើយថា ចាំយក

ទៅថ្លែងថ្នាក់ដឹកនាំ គ.ជ.ប សិន ហើយបាត់រហូតពុំមានចម្លើយយ៉ាងណាផង បែរជា គ.ជ.ប ចេញសេចក្តីសម្រេចបដិសេធចោលភាពមិនប្រក្រតីកាន់តែធ្ងន់ធ្ងរ ដែលខ្ញុំបានរកឃើញថែមទៀតនោះតែម្តង។

*ករណីទី៣ ៖ ខ្ញុំទាមទារសុំឲ្យ គ.ជ.ប ពិនិត្យ និងរាប់សន្លឹកឆ្នោតមិនបានការក្នុង៧២ការិយាល័យ ដូចមានបញ្ជាក់ភ្ជាប់មកជាមួយឯកសារក្នុងឧបសម្ព័ន្ធ២ ដោយហេតុថាតំណាងគណបក្សសង្គ្រោះជាតិនៅមូលដ្ឋានបានផ្តល់សេចក្តីរាយការណ៍ថា មន្ត្រីរាប់សន្លឹកឆ្នោតនៃការិយាល័យរាប់សន្លឹកឆ្នោតទាំងនោះរាប់លឿនពេក និងមានការបន្លំសន្លឹកឆ្នោតបានការ នាំឲ្យសន្លឹកឆ្នោតបានការរបស់គណបក្សសង្គ្រោះជាតិត្រូវបានគេដាក់ចូលទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ហើយតំណាងគណបក្សបានធ្វើការតវ៉ាដែរ តែមន្ត្រីរាប់សន្លឹកឆ្នោតមិនព្រម ដែលជាហេតុនាំឲ្យការិយាល័យទាំងនោះមានសន្លឹកឆ្នោតមិនបានការមានចំនួនច្រើនខុសប្លែកពីការិយាល័យផ្សេងទៀត ដែលមិនមានភាពមិនប្រក្រតី។ ចំពោះតំណាងគណបក្សសង្គ្រោះជាតិដែលសង្កេតការណ៍នៅការិយាល័យទាំងនោះ បានចុះហត្ថលេខាលើទម្រង់១១០២ មិនមែនមានន័យថាយល់ព្រមទទួលស្គាល់លើលទ្ធផលនៃការបោះឆ្នោតឬទទួលស្គាល់ថាមិនមានភាពមិនប្រក្រតីនៅក្នុងការិយាល័យបោះឆ្នោតទាំងនោះឡើយ។ បើតំណាងគណបក្សនយោបាយបានចុះហត្ថលេខាលើទម្រង់១១០២ ចាត់ទុកជាការទទួលស្គាល់លទ្ធផលបោះឆ្នោត ឬទទួលស្គាល់ថាមិនមានភាពមិនប្រក្រតីនៅក្នុងការិយាល័យបោះឆ្នោតយកជាបានការរួចទៅហើយ នោះមិនចាំបាច់ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មាត្រា១១៤ ទុកសិទ្ធិឲ្យគណបក្សនយោបាយធ្វើការប្តឹងតវ៉ាលើលទ្ធផលបោះឆ្នោតបណ្តោះអាសន្ននោះទេ។

ផ្អែកតាមភាពមិនប្រក្រតីធ្ងន់ធ្ងរទាំងបីករណីខាងលើនេះ បានធ្វើឲ្យប៉ះពាល់ដល់លទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិនៅមណ្ឌលខេត្តកណ្តាលធ្ងន់ធ្ងរខ្លាំងណាស់ តែបែរជា គ.ជ.ប សម្រេចសេចក្តីទាំងបំពានច្បាប់ និងបទបញ្ជា នីតិវិធី បដិសេធពាក្យបណ្តឹងរបស់ខ្ញុំចោលដោយស្ងាត់ៗ ដោយមិនបើកសវនាការសាធារណៈ ដើម្បីដោះស្រាយបណ្តឹងស្របតាមមាត្រា១១៤ និង១១៦ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីបញ្ជាក់ពីតម្លាភាព ឲ្យអ្នកឈ្នះ ឈ្នះដោយកិត្តិយស និងអ្នកចាញ់ ចាញ់ដោយអស់ចិត្ត។

ក្នុងរឿងនេះ ខ្ញុំសំណូមពរសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចលេខ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គ.ជ.ប ចោលជាអសារបង់ ហើយខ្ញុំស្នើសុំទាមទារដល់ក្រុមប្រឹក្សាធម្មនុញ្ញមេត្តាចេញសេចក្តីសម្រេច ៖

១- បង្គាប់ឲ្យ គ.ជ.ប រៀបចំការបោះឆ្នោតសារជាថ្មីនៅការិយាល័យលេខ ១២០៤ ឃុំស្វាយជ្រុំ ស្របតាមមាត្រា ១១៦ថ្មីនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

២- បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីយកទម្រង់ ១១០២ និង១១០៨ ធ្វើការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតចំនួន៨ការិយាល័យ នៅសង្កាត់តាខ្មៅ គឺការិយាល័យលេខ

១០៦៨, ១០៧១, ១១៨១, ១១៥៦, ១២៣៨, ១២៩១ និង ១២៩២ ដែលបាត់ទម្រង់ ១១០៨ ហើយត្រូវផ្តល់សុពលភាពលើលទ្ធផលបោះឆ្នោតតាមការិយាល័យនីមួយៗបើរកឃើញមានការប្រែប្រួល។

៣- បង្គាប់ឲ្យ គ.ជ.ប បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីយកសន្លឹកឆ្នោតមិនបានការទាំង៧២ ការិយាល័យ ដូចមានបញ្ជាក់លេខការិយាល័យក្នុងឧបសម្ព័ន្ធ២ មកពិនិត្យផ្ទៀងផ្ទាត់ និងផ្តល់សុពលភាពលើសន្លឹកមិនបានឡើងវិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមឯកឧត្តមប្រធាន មេត្តាផ្តល់នូវភាពយុត្តិធម៌ដល់គណបក្សសង្គ្រោះជាតិ តាមការស្នើសុំទៅតាមផ្លូវច្បាប់ ដោយអនុគ្រោះ។

សូមឯកឧត្តមប្រធានមេត្តាទទួលនូវការគោរពដោយស្មោះអំពីខ្ញុំ។

*រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣*

**ហត្ថលេខានិងឈ្មោះ**

**អេង ឆៃអ៊ាង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៨១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស សានគូ ខេមបូ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស សានកូ ខេមបូ** (SANCO CAMBO SEZ) ដែលមានទីតាំងស្ថិតនៅ ភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស សានកូ ខេមបូ** មានទំហំ ៦៦៥,០២៤ ម$^{២}$ (ប្រាំមួយរយហុកសិបប្រាំពាន់ និងម្ភៃបួនម៉ែត្រក្រឡា) ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស សានកូ ខេមបូ** ដូចមានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស សានកូ ខេមបូ** នេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងក្រុមហ៊ុន សានកូ ខេមបូ អ៊ិនវែសមេន គ្រុប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងខ្លួនៗ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

ដើម្បីសុំចុះហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តា សោភា**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៨៣៧...អនក្រ -៥៥

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូន មន្ត្រីរាជការ មន្ត្រីនគរបាលជាតិ និងសប្បុរសជន ចំនួន ៣០រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ សុខាភិបាល សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងជួយឧបត្ថម្ភដល់កាកបាទក្រហមខេត្ត នៅក្នុងខេត្តព្រះសីហនុ ដែលមានរាយនាមដូចខាងក្រោម :

១-លោកវរសេនីយ៍ឯក **អ៊ឹម ឈួន**
២-លោកវរសេនីយ៍ឯក **លឹម ទុយ្យ៉ិនធារ៉ា**
៣-លោកវរសេនីយ៍ទោ **យិន លឹម**
៤-លោកវរសេនីយ៍ទោ **ម៉ា ញៀម**
៥-លោកវរសេនីយ៍ទោ **ម៉ែន ខេមរិទ្ធ**
៦-លោកវរសេនីយ៍ទោ **ឌុន សាខាន់**
៧-លោកវរសេនីយ៍ត្រី **ខាត់ សារ៉ុំ**
៨-លោកវរសេនីយ៍ត្រី **ជាវ ទិបុល**
៩-លោកវរសេនីយ៍ត្រី **ញៀម អូន**
១០-លោកវរសេនីយ៍ត្រី **គង់ ទិចិត្រ**

១១-លោកវរសេនីយ៍ត្រី សែម គន្ធា
១២-លោកវរសេនីយ៍ត្រី អ៊ាន់ លីហោ
១៣-លោកវរសេនីយ៍ត្រី ខឹន សារ៉ែម
១៤-លោកវរសេនីយ៍ត្រី ស្រ៊ុន សុជាតិ
១៥-លោកវរសេនីយ៍ត្រី ញ៉ៀម ចាន់ថូ
១៦-លោកអនុសេនីយ៍ឯក ចាន់ សំបាន
១៧-លោកអនុសេនីយ៍ឯក ស៊ា ស៊ីណាល់
១៨-លោកអនុសេនីយ៍ឯក ប៉ែន តារា
១៩-លោកអនុសេនីយ៍ទោ ឆូច សម្បត្តិ
២០-លោកអនុសេនីយ៍ទោ សុផាន សមសក្តិ
២១-លោកអនុសេនីយ៍ត្រី ខិន សុម៉ារ៉ាឡែន
២២-លោកអនុសេនីយ៍ត្រី ជា ម៉េងលាង
២៣-លោកអនុសេនីយ៍ត្រី សម្បត្តិ កុសល
២៤-លោក ហេង សំបូរ
២៥-លោក អៀង សារ៉ាន
២៦-លោក ថៃ ធី
២៧-លោក សេង សំអូន
២៨-លោក ប្រាក់ កុសល
២៩-លោក ផាង ឡេងង៉ោ
៣០-លោក ឈុត សារ៉ែន

**មាត្រា ២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៨៨០...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្តល់ជូន មន្ត្រីរាជការ និងមន្ត្រីនគរបាលជាតិ ចំនួន ៤១រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ សុខាភិបាល សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងជួយឧបត្ថម្ភដល់កាកបាទក្រហមខេត្ត នៅក្នុងខេត្តព្រះសីហនុ ដែលមានរាយនាមដូចខាងក្រោម :

១-លោកឧត្តមសេនីយ៍ត្រី **ឆាយ ប៊ុណ្ណា**
២-លោកវរសេនីយ៍ឯក **លឹម ទុឡារិន**
៣-លោកវរសេនីយ៍ទោ **ចាន់ សុគ័ន្ធ្រា**
៤-លោកវរសេនីយ៍ទោ **ស៊ុន សុផាត**
៥-លោកវរសេនីយ៍ត្រី **ទទ្យ ណារុធ**
៦-លោកវរសេនីយ៍ត្រី **តា សំអាត**
៧-លោកអនុសេនីយ៍ឯក **ឡុច ហេង**
៨-លោកអនុសេនីយ៍ឯក **ថូ រចនាឌី**
៩-លោកអនុសេនីយ៍ឯក **សុខ សំអាត**
១០-លោកអនុសេនីយ៍ឯក **ចាន់ មករា**
១១-លោកអនុសេនីយ៍ឯក **ប៉េង អេងហាក់**
១២-លោកអនុសេនីយ៍ឯក **អឿន សុខា**
១៣-លោកអនុសេនីយ៍ទោ **ឡាយ ម៉ុង**
១៤-លោកអនុសេនីយ៍ទោ **ច្រឹប ចាន់ធា**
១៥-លោកអនុសេនីយ៍ទោ **តៅ ឆេងហៃ**

១៦-លោកអនុសេនីយ៍ទោ ជឹម ចណ្ណៈ
១៧-លោកអនុសេនីយ៍ទោ ឡឿ អាត
១៨-លោកអនុសេនីយ៍ទោ ស៊ុ ម៉ូរ៉ាណាល់
១៩-លោកអនុសេនីយ៍ទោ ឃិត សេរី
២០-លោកអនុសេនីយ៍ទោ ហេង សំណាងវុធ
២១-លោកអនុសេនីយ៍ទោ សុខ សារឿនមុនី
២២-លោកអនុសេនីយ៍ទោ ឃុន ពេជ្រតារាណា
២៣-លោកអនុសេនីយ៍ទោ កេះ សារ៉េម
២៤-លោកអនុសេនីយ៍ទោ យី ជូនី
២៥-លោកអនុសេនីយ៍ទោ ហេង គឹមអាន
២៦-លោកអនុសេនីយ៍ទោ ខួន ស៊ីថា
២៧-លោកអនុសេនីយ៍ត្រី សាន្ត រដ្ឋា
២៨-លោកអនុសេនីយ៍ត្រី សម្បត្តិ កុសលណារ៉ា
២៩-លោកអនុសេនីយ៍ត្រី ជា ណាវ៉ាន
៣០-លោកអនុសេនីយ៍ត្រី ចិន សម៉ាឡែន
៣១-លោកអនុសេនីយ៍ត្រី ស៊ុយ សុភាព
៣២-លោកអនុសេនីយ៍ត្រី ហេង គា
៣៣-លោកអនុសេនីយ៍ត្រី ស្វាយ ដារ៉ា
៣៤-លោកអនុសេនីយ៍ត្រី អ៊ុក ឌីណា
៣៥-លោកអនុសេនីយ៍ត្រី ឃាង សុជាតិ
៣៦-លោកអនុសេនីយ៍ត្រី រ័ត្ន ថាវឌ្ឍ
៣៧-លោកព្រិន្ទបាលទោ ចុល ចេក
៣៨-លោកព្រិន្ទបាលទោ ញឹម ពិសិដ្ឋ
៣៩-លោក ចាន់ ម៉ារឌី
៤០-លោក ឆេង សាវិន
៤១-លោក ម៉ន សារុំ

**មាត្រា ២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល :__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]

# អនុក្រឹត្យ
## ស្តីពីការជូនគ្រឿងឥស្សរិយយសសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសសុវត្ថារា** តាមលំដាប់ថ្នាក់ ផ្តល់ជូន សប្បុរសជន មន្ត្រីរាជការ និងមន្ត្រីនគរបាលជាតិចំនួន ៣៤ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ សុខាភិបាល សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងជួយឧបត្ថម្ភដល់កាកបាទក្រហមខេត្ត នៅក្នុងខេត្តព្រះសីហនុ ដែលមានរាយនាមដូចខាងក្រោម :

**ក–មេដាយសុវត្ថារាថ្នាក់ធិបឌិន្ទចំនួន ៣១ គ្រឿង ផ្តល់ជូន :**

១-លោកវរសេនីយ៍ទោ ឌុន សុខា
២-លោកវរសេនីយ៍ទោ នៅ ស៊ីវណ្ណា
៣-លោកវរសេនីយ៍ត្រី វ៉ាន លីហោ
៤-លោកវរសេនីយ៍ត្រី ឯម សារួន
៥-លោកវរសេនីយ៍ត្រី ហេង វីរៈ
៦-លោកអនុសេនីយ៍ឯក នុំ ផល្លី
៧-លោកអនុសេនីយ៍ឯក ឯក សុផាតារ៉ា
៨-លោកអនុសេនីយ៍ឯក សឹ សុផល
៩-លោកអនុសេនីយ៍ឯក អឿន សុខា
១០-លោកអនុសេនីយ៍ឯក គីម ស៊ី
១១-លោកអនុសេនីយ៍ឯក ជា សំអាត

| | | |
|---|---|---|
| ១២-លោកអនុសេនីយ៍ឯក | មុនី | សីហា |
| ១៣-លោកអនុសេនីយ៍ឯក | គុយ | ម៉េង |
| ១៤-លោកអនុសេនីយ៍ឯក | កែវ | សុខា |
| ១៥-លោកអនុសេនីយ៍ទោ | សុខ | សារឿន |
| ១៦-លោកអនុសេនីយ៍ទោ | ចាន់ | ម៉ារ៉ែន |
| ១៧-លោកអនុសេនីយ៍ទោ | ហេង | សំណាង |
| ១៨-លោកអនុសេនីយ៍ទោ | ឃុន | ពេជ្រតារា |
| ១៩-លោកអនុសេនីយ៍ទោ | ឆាយ | ប៊ុណ្ណារិទ្ធ |
| ២០-លោកអនុសេនីយ៍ទោ | អឿង | អង្គារិទ្ធ |
| ២១-លោកអនុសេនីយ៍ត្រី | ជាង | មនោរិន |
| ២២-លោកអនុសេនីយ៍ត្រី | មួង | សេងហួង |
| ២៣-លោកអនុសេនីយ៍ត្រី | សម្បត្តិ | កុសលតា |
| ២៤-លោកអនុសេនីយ៍ត្រី | តឹក | ចំនួសុធា |
| ២៥-លោកអនុសេនីយ៍ត្រី | ណាំ | ប៊ុនវ៉ៃ |
| ២៦-លោកអនុសេនីយ៍ត្រី | ពិន | សូដែន |
| ២៧-លោកអនុសេនីយ៍ត្រី | សោ | ប៊ុនលាង |
| ២៨-លោក | ជ | ចាន់ស៊ាង |
| ២៩-លោក | ស៊ុំ | សុផល |
| ៣០-លោក | ឆេង | សារិទ្ធ |
| ៣១-លោក | លី | សេងហ៊ុយ |

ខ- មេដាយសុវត្ថារាជ្ញថ្នាក់សេនាចំនួន ០៣ គ្រឿង ផ្តល់ជូន :

| | | |
|---|---|---|
| ១-លោកអនុសេនីយ៍ឯក | សំ | សាម៉ុឌី |
| ២-លោកអនុសេនីយ៍ត្រី | ជា | ណាវ៉ាន់ថា |
| ៣-លោក | ខាត់ | សារ៉ាន់ |

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៩៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូន សប្បុរសជន មន្ត្រីរាជការ និងមន្ត្រីនគរបាលជាតិចំនួន ៤០រូប ដែលបានលះបង់កំលាំងកាយចិត្តនិងបរិច្ចាគថវិកាផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ សុខាភិបាល សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងជួយឧបត្ថម្ភដល់កាកបាទក្រហមខេត្ត នៅក្នុងខេត្តព្រះសីហនុ ដែលមានរាយនាមដូចខាងក្រោម :

**ក-មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ២៩ គ្រឿង ផ្តល់ជូន :**

១-លោកវរសេនីយ៍ត្រី **ខង្ស សារី**
២-លោកវរសេនីយ៍ត្រី **ហ្វូ ចំនួថា**
៣-លោកវរសេនីយ៍ត្រី **ព្រុំ ភារះ**
៤-លោកវរសេនីយ៍ត្រី **តន់ ចំនួណារ៉ា**
៥-លោកវរសេនីយ៍ត្រី **ចាន់ វិន្ធូ**
៦-លោកវរសេនីយ៍ត្រី **អន ឈុន**
៧-លោកវរសេនីយ៍ត្រី **អ៊ុយ សារ៉ាត់**
៨-លោកវរសេនីយ៍ត្រី **ឃាន ម៉ិនឡៀន**
៩-លោកវរសេនីយ៍ត្រី **កាក់ កើត**
១០-លោកអនុសេនីយ៍ឯក **ឯក សុផាត**
១១-លោកអនុសេនីយ៍ឯក **ជុំ សារ៉ន**
១២-លោកអនុសេនីយ៍ឯក **កែវ សុខ**

១៣-លោកអនុសេនីយ៍ទោ ចន ចំនួពុទ្ធត្រា
១៤-លោកអនុសេនីយ៍ត្រី តាំង ឈ្នួនខៀប
១៥-លោកអនុសេនីយ៍ត្រី ញៀត ស៊ីណាន
១៦-លោកអនុសេនីយ៍ត្រី ខៃ សុវណ្ណ
១៧-លោកអនុសេនីយ៍ត្រី ហ៊ឹង វណ្ណៈ
១៨-លោកអនុសេនីយ៍ត្រី សេង រ័ត្នរិទ្ធ
១៩-លោកអនុសេនីយ៍ត្រី មួង សេងហួងវ៉ា
២០-លោកអនុសេនីយ៍ត្រី ព្រាំ រ័ត្នធា
២១-លោកអនុសេនីយ៍ត្រី តឹក ចំនួសុធារ៉ា
២២-លោកអនុសេនីយ៍ត្រី រ៉េន គុណរចនា
២៣-លោកព្រិន្ទបាលឯក ឡឹក ជីវ័ន្ត
២៤-លោកព្រិន្ទបាលឯក ម៉ូវ ធីណាយ
២៥-លោក គង់ សុម៉ាឡា
២៦-លោក តូច រៀប
២៧-លោក គង់ វីតាណៈ
២៨-លោក ឃុត សាលីន
២៩-លោក បាន សេដា

ខ- មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនាចំនួន ១១ គ្រឿង ផ្តល់ជូន :

១-លោកវរសេនីយ៍ឯក ហាន្យ មូរ
២-លោកអនុសេនីយ៍ឯក ថូ រចនា
៣-លោកអនុសេនីយ៍ឯក ឯម វណ្ណារ៉ា
៤-លោកអនុសេនីយ៍ទោ ច្រឹប ថាវុធ
៥-លោកអនុសេនីយ៍ទោ រិទ្ធ ចាន់ណារ៉ា
៦-លោកអនុសេនីយ៍ទោ ចេង សុផល
៧-លោកអនុសេនីយ៍ទោ កែវ សុភ័ណ្ឌ
៨-លោកអនុសេនីយ៍ទោ ឡេង ទៅ
៩-លោកអនុសេនីយ៍ទោ យី ជួន
១០-លោកអនុសេនីយ៍ត្រី ហ៊ិន សុភ័ក្ត្រ
១១-លោក រ៉ិត គង់

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៨៨៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីរាជការ និងសប្បុរសជន ចំនួន ០៤រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រកន្លងមក ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | **ខន សាវ៉ុន** | អគ្គលេខ ២៣២២៨៦ បញ្ជាការរងកងអន្តរាគន៍៥៩៤ ក្រសួងការពារជាតិ |
| ២-លោក | **នូ សំអាត** | អភិបាលស្រុកប្រាសាទបាគង |
| ៣-លោក | **អឿម សុជាតិ** | ប្រធានក្រុមប្រឹក្សាស្រុកប្រាសទបាគង |
| ៤-លោក | **ឡុង ចាន់រិទ្ធ** | សប្បុរសជន |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៩៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

### សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងសប្បុរសជន ចំនួន ២៩រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | |
|---|---|
| ១-លោក **សាន វណ្ណារ៉ា** | សប្បុរសជនរាជធានីភ្នំពេញ |
| ២-លោក **អ៊ឹម ពិរុណ** | មន្ត្រីខុទ្ទកាល័យសម្តេចចក្រីប្រធានរដ្ឋសភា |
| ៣-លោក **យិន ផលលិក** | សប្បុរសជនរាជធានីភ្នំពេញ |
| ៤-លោកស្រី **អ៊ុំ សុគីយ៉ាន** | សប្បុរសជនរាជធានីភ្នំពេញ |
| ៥-លោក **មាស សន** | សប្បុរសជនរាជធានីភ្នំពេញ |
| ៦-លោក **ឈុំ សុវណ្ណ** | សប្បុរសជនរាជធានីភ្នំពេញ |
| ៧-លោក **ឈា ចាន់ណា** | សប្បុរសជនរាជធានីភ្នំពេញ |
| ៨-លោក **ម៉ុល សម្បត្តិ** | សប្បុរសជនរាជធានីភ្នំពេញ |
| ៩-លោក **ដាយ សារិទ្ធិ** | សប្បុរសជនរាជធានីភ្នំពេញ |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | |
|---|---|
| ១-លោក **នាយ ថេង** | សប្បុរសជនរាជធានីភ្នំពេញ |
| ២-លោក **ឡាំ សុជាតិ** | សប្បុរសជនរាជធានីភ្នំពេញ |
| ៣-លោក **ស្រ៊ុន សារក្ស** | សប្បុរសជនរាជធានីភ្នំពេញ |
| ៤-លោក **ស៊ិន រ៉ុន** | សប្បុរសជនរាជធានីភ្នំពេញ |

| | |
|---|---|
| ៥-លោកស្រី អ៊ុក សាទី | សប្បុរសជនរាជធានីភ្នំពេញ |
| ៦-លោក សាត បូរ៉ាមី | សប្បុរសជនរាជធានីភ្នំពេញ |
| ៧-លោក ម៉ែន បូរីណា | សប្បុរសជនរាជធានីភ្នំពេញ |
| ៨-លោក ខិន សំអឿន | សប្បុរសជនរាជធានីភ្នំពេញ |
| ៩-លោក អឿន សុខសីហា | សប្បុរសជនរាជធានីភ្នំពេញ |
| ១០-លោក ទឹម សុផាន់ណា | សមាជិកក្រុមប្រឹក្សាសង្កាត់អូរឫស្សី៤ |
| ១១-លោក សៀង សារុន | សមាជិកក្រុមប្រឹក្សាសង្កាត់អូរឫស្សី៤ |
| ១២-លោក អ៊ុំ សំអឿន | មន្ត្រីសង្កាត់អូរឫស្សី៤ |
| ១៣-វរសេនីយ៍ត្រី សួន វណ្ណៈ | អត្ត.៣៣៤០៥ នាយនគរបាលក្រសួងមហាផ្ទៃ |
| ១៤-វរសេនីយ៍ត្រី យ៉ឹម ឃួន | អត្ត.៣៣៨៨១ នាយនគរបាលក្រសួងមហាផ្ទៃ |
| ១៥-វរសេនីយ៍ត្រី អ៊ុំ សំអាង | អត្ត.៣៤០៦០ នាយនគរបាលក្រសួងមហាផ្ទៃ |
| ១៦-វរសេនីយ៍ត្រី រស់ សាវ៉ាត | អត្ត.៣៣៦៥៩ នាយនគរបាលក្រសួងមហាផ្ទៃ |
| ១៧-អនុសេនីយ៍ឯក នោ សុផុន | អត្ត.៣៣៨៩០ នាយនគរបាលក្រសួងមហាផ្ទៃ |
| ១៨-អនុសេនីយ៍ឯក ហុក គឹមហាន | អត្ត.៣៩០៨១ នាយនគរបាលក្រសួងមហាផ្ទៃ |
| ១៩-អនុសេនីយ៍ត្រី ឈាន នឹម | អត្ត.៣៩៣១៧ នាយនគរបាលក្រសួងមហាផ្ទៃ |
| **គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ** | |
| -លោក ម៉ា ម៉ិតតូ | សប្បុរសជនរាជធានីភ្នំពេញ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨០៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងសប្បុរសជន ចំនួន ១៧រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមជួយកសាងសមិទ្ធផលនានា ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ សម្រេចបានលទ្ធផលល្អប្រសើរ ដូចមាននាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

១-លោក **ម៉ី ចាន់សាទតា** សប្បុរសជនរាជធានីភ្នំពេញ

២-លោក **ឆន កែវមុនីរ័ត្ន** សប្បុរសជនរាជធានីភ្នំពេញ

៣-លោក **ម៉ែន សំបុក** សប្បុរសជនរាជធានីភ្នំពេញ

៤-លោក **ជា ចាន់ដារ៉ា** សប្បុរសជនរាជធានីភ្នំពេញ

៥-លោក **អ៊ឹម នឿន** សប្បុរសជនរាជធានីភ្នំពេញ

៦-វរសេនីយ៍ត្រី **សេខ ទុន្លា** អត្ត.២៥២៥២ នាយការិយាល័យសន្តិសុខផ្ទៃក្នុងស្នងការដ្ឋាននគរបាល ខេត្តស្ទឹងត្រែង

៧-អនុសេនីយ៍ឯក **ត្រី វ៉ាឌី** អត្ត.៦៧៦៩៤ នាយផ្នែកបុគ្គលិកស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង

៨-វរសេនីយ៍ទោ **ហ៊ីង ចាន់ថន** អត្ត.០៣០៥៣ នាយការិយាល័យសុខាភិបាលស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង

៩-អនុសេនីយ៍ត្រី **យឹម បញ្ញា** អត្ត.៦៣៥៧៤ នាយរងផ្នែកការិយាល័យសណ្តាប់ធ្នាប់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង

១០-ព្រិន្ទបាលទោ **ជុន បូរី** អត្ត.៧០៦៣៨ មន្ត្រីអធិការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង

១១-វរសេនីយ៍ត្រី **ទី សុខ** អត្ត.០១១៦៨៤ នាយរងការិយាល័យផែនការគណនេយ្យស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង

១២-អនុសេនីយ៍ឯក **ឱុយ ចន្ទ្រា** អត្ត.០១១៦៤២ នាយផ្នែកការិយាល័យសណ្តាប់ធ្នាប់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង

១៣-វរសេនីយ៍ត្រី **ខែម ទិបុល** អត្ត.០៨៩៥៩ អធិការនគរបាលស្រុកទឹកផុសស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង

១៤-វរសេនីយ៍ត្រី **ជួន ហុង** អត្ត.២៨៨៨១ អធិការនគរបាលស្រុកសាមគ្គីមានជ័យ ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង

| | |
|---|---|
| ១៥-លោក **ម៉ៅ សំអាន** | សមាជិកក្រុមការងារចុះជួយឃុំវាលម្លូ ស្រុកពញាក្រែក ខេត្តកំពង់ចាម |
| ១៦-ព្រិន្ទបាលទោ **ស្លេះ យ៉ាក់ហ្វើត** | អត្ត.៤៣៩៤៣ មន្ត្រីនគរបាលក្រុងបាត់ដំបង |

**ខ-មេដាយសិរីវឌ្ឍនភាពមាស**

| | |
|---|---|
| -លោក ហោ តុលា | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ ...៦៦៥... ឧរម.ឧ.ក.ស./ ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ១៣៨/១៣ គ.គ.ស.ព ចុះថ្ងៃទី២៦.០៨.២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អេស៊ា លីឌើរ អ៊ិនធើណេសិនណល (ខេមបូឌា) ចុះថ្ងៃទី ០៨.០៧.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន អេស៊ា លីឌើរ អ៊ិនធើណេសិនណល (ខេមបូឌា) (ASIA LEADER INTERNATIONAL (CAMBODIA) Co., Ltd.) តំណាង ដោយ លោក GUOJIAN CHEN សញ្ជាតិអាមេរិក អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 482529339 ចុះថ្ងៃទី ២២.០៨.២០១១ មានអាសយដ្ឋានបច្ចុប្បន្ន៖ 1754 19th Ave Sf. Ca94122 U.S.A. ជាម្ចាស់រោងចក្រ ធ្វើការបង្កើត រោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| កង់ជិះ: | ៣០៩២ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855 23 211141, Fax : 855 23 428263

**ផ្លាកឈ្មោះរោងចក្រ ៖** " *រោងចក្រតម្លើងកង់ អេស៊ា លីឌើរ អ៊ិនធើណេសិនណល (ខេមបូឌា)* "

**ទីតាំងរោងចក្រ ៖** " *តំបន់សេដ្ឋកិច្ចពិសេសតាយសេងបាវិត សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង* "

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

<u>ចម្លងជូន:</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តស្វាយរៀង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ៦៦៦ ឧរថ.កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ១៥០ /១១ ម.ត.ស.ព ចុះថ្ងៃទី០៦.០៤.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន វ៉ល លី ផេកខេកជីង (ខេមបូឌា) ចុះថ្ងៃទី០៩.០៧.២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន វ៉ល លី ផេកខេកជីង (ខេមបូឌា) (WALLY PACKAGING (CAMBODIA) CO., LTD.) តំណាងដោយ លោក YUE LIANG សញ្ជាតិចិន អាយុ២៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខG44887804 ចុះថ្ងៃទី២០.០៨.២០១០ មានអាសយដ្ឋានបច្ចុប្បន្ន៖ Huantai Zibo City, Shandong, P.R. China. ជាម្ចាស់ រោងចក្រធ្វើការបង្កើតរោងចក្រលើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| ថង់ និងសម្ភារៈវេចខ្ចប់ពីប្លាស្ទិក | ២២២០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រផលិតថង់ និងសម្ភារៈវេចខ្ចប់ វ៉ៃ លី ផេកខេកជីង (ខេមបូឌា) "*

**ទីតាំងរោងចក្រ ៖** *" តំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន ស្វាយរៀង សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចដូល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុង ប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការ រោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុង ប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួល ទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់ សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

<u>ចម្លងជូន:</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តស្វាយរៀង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៨ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ